ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គជអប
NCDD

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)

# របាយការណ៍ប្រចាំឆ្នាំ២០២១

# ស្តីពី

# ការអនុវត្តផែនការសកម្មភាព និងថវិកា ឆ្នាំ២០២១

# របស់ គ.ជ.អ.ប.

រៀបចំដោយ ៖ លេខាធិការដ្ឋាន គ.ជ.អ.ប.

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គជអប

NCDD

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)

# របាយការណ៍ប្រចាំឆ្នាំ២០២១

## ស្តីពី

# ការអនុវត្តផែនការសកម្មភាព និងថវិកា ឆ្នាំ២០២១

## របស់ គ.ជ.អ.ប.

រៀបចំដោយ ៖ លេខាធិការដ្ឋាន គ.ជ.អ.ប.

# អារម្ភកថា

ផែនការសកម្មភាព និងថវិកាឆ្នាំ២០២១ របស់គ.ជ.អ.ប. គឺជាឆ្នាំតភ្ជាប់រវាងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី១ពីឆ្នាំ២០១០ដល់ឆ្នាំ២០២០ (កជទី១) និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាល ទី២ពីឆ្នាំ២០២១ដល់ឆ្នាំ២០៣០ (កជទី២) ដែលបានអនុម័តដោយរាជរដ្ឋាភិបាលនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ ២០២១។ ក្នុងន័យនេះ ផ.ស.ថ. ឆ្នាំ២០២១ គឺជាផែនការអន្តរកាលដែលបានរៀបចំក្នុងអំឡុងពេលរៀបចំតាក់តែង កជទី២។

របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២១នៃការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២១ របស់ គ.ជ.អ.ប. គ្របដណ្តប់រយៈពេលពីខែមករា-ធ្នូ ឆ្នាំ២០២១។ ជារួម ទោះបីក្នុងឆ្នាំ២០២១ យើងបានជួបប្រទះនូវបញ្ហា ដ៏ធ្ងន់ធ្ងរនៃជំងឺឆ្លងរាតត្បាតកាចសាហាវកូវីដ-១៩ក៏ដោយ ក៏យើងបានសម្រេចនូវលទ្ធផលសំខាន់ៗគួរឱ្យកត់សម្គាល់មួយចំនួនមានដូចជា ឯកសារ កជទី២ ត្រូវបានរៀបចំ និងអនុម័តដោយរាជរដ្ឋាភិបាលនៅ ថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០២១ ហើយសេចក្តីព្រាងបឋមនៃផែនការអនុវត្ត៥ឆ្នាំដំណាក់កាលទី១ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥ (ផអ៥ទី១) ត្រូវបានរៀបចំ ដោយមានជំនួយបច្ចេកទេសពីក្រុមទីប្រឹក្សាជាតិ និងអន្តរជាតិដែលគាំទ្រដោយ EU, GIZ និង SDC។ សូចនាករត្រួតពិនិត្យរួមគ្នាពីឆ្នាំ២០២១-២០២៣ (JMI) ត្រូវបានរៀបចំនិងដាក់ជូន CDC កម្មវិធីការងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ពាក់ព័ន្ធនឹងការលើកកម្ពស់ភាព បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុពីឆ្នាំ២០២១-២០២៥ និងឯកសារទស្សនទានស្តីពីគម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុដំណាក់កាលទី៣ (LGCC3) បានកែសម្រួលជាចុងក្រោយ និងដាក់ជូន GCF ដើម្បីស្នើសុំការគាំទ្រមូលនិធិ។

គម្រោងគាំទ្រ ISAF ដំណាក់កាលទី២ (២០១៩-២០២៣) ត្រូវបានអនុវត្ត និងដាក់ឱ្យដំណើរការ វគ្គបណ្តុះបណ្តាលអំពី ISAF ដល់ស្រុក និងឃុំគោលដៅថ្មីត្រូវបានរៀបចំ និងការបញ្ចូលទិន្នន័យអំពីលទ្ធផលការងារនៃការផ្តល់សេវារបស់អង្គភាពផ្តល់សេវាទាំង៣សម្រេចបានជាង៨០%។ មន្ត្រីការិយាល័យប្រជាពលរដ្ឋចំនួន១១៥នាក់ ទទួលបាននូវការបំប៉នសមត្ថភាពបន្ថែមអំពីយន្តការសម្រុះសម្រួល និងដោះស្រាយបណ្តឹង ហើយបណ្តឹងក្នុងសមត្ថកិច្ចចំនួនជាង៩០% ត្រូវបានសម្រុះសម្រួលដោះស្រាយដោយការិយាល័យប្រជាពលរដ្ឋនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

ចំពោះការគ្រប់គ្រងធនធានមនុស្ស យើងបានរៀបចំទិន្នន័យដើមគ្រា និងបញ្ជីបុគ្គលិកដែលបានផ្ទេរទៅ ឱ្យរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំ និងធ្វើសមាហរណកម្មចូលទៅក្នុងតារាងប្រាក់បៀវត្សរបស់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ គោលការណ៍បែបបទ និងនីតិវិធីសម្រាប់ការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានពិនិត្យ និងកែសម្រួលស្របតាមរចនាសម្ព័ន្ធ និងមុខងារ ថ្មីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរជំនាញ បានរៀបចំ និងអនុវត្តសកម្មភាពអភិវឌ្ឍសមត្ថភាពនានាពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការចំនួនជាង៥០០សកម្មភាពដល់មន្ត្រីរបស់ខ្លួន និងមន្ត្រីនៃរដ្ឋបាលឃុំ សង្កាត់ចំនួនជាង

១០.០០០នាក់។

មូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌសម្រាប់ការអនុវត្តមុខងារក្នុងវិស័យអប់រំ និងសុខាភិបាល និងថវិកាឧបត្ថម្ភធនការិយាល័យជំនាញនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវវិភាជ និងផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។ ពាក់ព័ន្ធនឹងកិច្ចការនេះ ក្រសួងចំនួន២០បាន និងកំពុងរៀបចំរៀបចំសេចក្ដីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌដែលក្នុងនោះក្រសួងចំនួន១៤បានរៀបចំបញ្ចប់សេចក្ដីណែនាំ និងបានរៀបចំវគ្គបណ្ដុះបណ្ដាលអំពីឯកសារនេះ។ យន្តការផ្ដល់សេវាច្រកចេញចូលតែមួយបានបន្តកិច្ចប្រតិបត្តិការរបស់ខ្លួនក្នុងការផ្ដល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ និងទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ ដោយបានផ្ដល់សេវាចំនួនជាង២លានសេវា និងទទួលបានចំណូលសរុបចំនួនប្រមាណជា២៤លានដុល្លារអាមេរិក។

ជាមួយនឹងលទ្ធផលដែលសម្រេចបានខាងលើ យើងបានក៏បានជួបប្រទះនូវបញ្ហាប្រឈមមួយ ដ៏ធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ដែលកំពុងរាតត្បាតពិភពលោករួមបញ្ចូលទាំងប្រទេសកម្ពុជាយើង និងបានធ្វើឱ្យសកម្មភាពជាច្រើនដែលបានគ្រោងក្នុងឆមាសទី១នេះទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានផ្អាកដំណើរការ ឬពន្យារពេលអនុវត្ត ជាពិសេសការរៀបចំតាក់តែងឯកសារ កជទី២ ផអ៥ទី១ និងការៀបចំ និងការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២១ របស់ គ.ជ.អ.ប. ក៏ដូចជា ផ.ស.ថ. របស់ក្រសួង ស្ថាប័ន រដ្ឋបាល ថ្នាក់ក្រោមជាតិ និងគម្រោង កម្មវិធីដាច់ដោយឡែកនានា។

ក្នុងនាម គ.ជ.អ.ប. ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីជាតំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានាដែលបានយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងក្នុងការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២១ ក៏ដូចជាការសម្រេចបាននូវលទ្ធផលសំខាន់ៗក្នុងឆ្នាំ២០២១។ ខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោក លោកស្រីនឹងបន្តកិច្ចខិតខំប្រឹងប្រែង និងចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២២នៃ កជទី២ ឱ្យសម្រេចបានលទ្ធផលនានាតាមការគ្រោងទុក។

ថ្ងៃ សុក្រ ១រោច ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០២២

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.**

**ថាន់ ចំរើន**

# មាតិកា

**អារម្ភកថា**...i
**មាតិកា** ...iii
**អក្សរកាត់** ...vi
**វាក្យសព្ទសំខាន់ៗ**...vii
១. សេចក្ដីផ្ដើម ...១
២. សេចក្ដីសង្ខេបអំពីវឌ្ឍនភាព...៣
៣. ស្ថានភាពហិរញ្ញវត្ថុ...១៨
៤. បញ្ហាប្រឈម និងដំណោះស្រាយ...១៩
៥. សម្មភាពជាអាទិភាពសម្រាប់ឆ្នាំ២០២២...២១
៦. សេចក្ដីសន្និដ្ឋាន ...២៣

**ឧបសម្ព័ន្ធ**
១. វឌ្ឍនភាពនៃការអនុវត្តសកម្មភាពជាអាទិភាពនីមួយៗ...២៥
២. វឌ្ឍនភាពនៃការអនុវត្តសកម្មភាពធៀបនឹងសូចនាករ...៣៩
៣. វឌ្ឍនភាពនៃការអនុវត្តថវិកាប្រចាំឆ្នាំ២០២១តាមស្ថាប័នអនុវត្ត...៤៣
៤. ស្ថានភាពនៃការគ្រប់គ្រងហានិភ័យ...៤៦

# អក្សរកាត់

| **អក្សរកាត់** | **ពាក្យពេញ** |
|---|---|
| RGC | រាជរដ្ឋាភិបាល |
| គ.ជ.អ.ប. | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| គ.ជ.វ.វ. | គណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និវិសហមជ្ឈការ |
| គ.ក.ស.ក. | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| គ.ក.ន.ក. | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| SNIF | មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ |
| CPs | រាជធានី ខេត្ត |
| DMKs | ក្រុង ស្រុក ខណ្ឌ |
| CS | ឃុំ សង្កាត់ |
| PDoWA | មន្ទីរកិច្ចនារី |
| PDoP | មន្ទីរផែនការរាជធានី ខេត្ត |
| D&D | វិមជ្ឈការ និងវិសហមជ្ឈការ |
| M&E | ការត្រួតពិនិត្យ និងការវាយតម្លៃ |
| I4C | ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ |
| ISAF | ការអនុវត្តផែនការគណនេយ្យភាពសង្គម |
| JAAP | ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម |
| SS | សេវាសង្គម |
| CC | ការប្រែប្រួលអាកាសធាតុ |
| CCA | ភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ |
| CD | ការអភិវឌ្ឍសមត្ថភាព |
| Sida | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសស៊ុយអែដ |
| EU | សហភាពអឺរ៉ុប |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ADB/PPTA | គម្រោងជំនួយបច្ចេកទេសសម្រាប់ការរៀបចំកម្មវិធី |
| ADB/DPFSM | កម្មវិធីស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងការផ្តល់សេវាសាធារណៈបែបវិមជ្ឈការ |
| ADB/TS-PRSDP | គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប |
| NASLA | សាលាជាតិរដ្ឋបាលមូលដ្ឋាន |
| IFAD | មូលនិធិអន្តរជាតិសម្រាប់កិច្ចអភិវឌ្ឍកសិកម្ម |
| IFAD/ASPIRE | គម្រោងផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីធន់នឹងការប្រែប្រួលអាកាសធាតុ |

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| SDC | ទីភ្នាក់ងារសហប្រតិបត្តិការសម្រាប់កិច្ចអភិវឌ្ឍរបស់ប្រទេសស្វីស |
| UNCDF | មូលនិធិសម្រាប់អភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ |
| UNCDF/LGCC | គម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ |
| UNICEF | មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ |
| UNDP/SRL | គម្រោងកាត់បន្ថយភាពរងគ្រោះនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ |
| UNDP/BESD | គម្រោងបង្កើតបរិយាកាសអំណោយផលប្រកបដោយចីរភាព |
| UNEP/EmPower | គម្រោងពង្រឹងសិទ្ធិអំណាចស្ត្រីដើម្បីសង្គមធន់នឹងការប្រែប្រួលអាកាសធាតុ |
| UNFPA | មូលនិធិប្រជាពលរដ្ឋរបស់អង្គការសហប្រជាជាតិ |
| WB | ធនាគារពិភពលោក |
| WB/LASED II | គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ជំហានទី២ |
| WB/CNP | គម្រោងអាហារូបត្ថម្ភកម្ពុជា |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក |
| WFP/SRELFOODS | គម្រោងពង្រឹងប្រព័ន្ធស្បៀងអាហារមូលដ្ឋានដែលមានភាពធន់ |
| GIZ/DAR | កម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ |
| USAID | ទីភ្នាក់ងារសម្រាប់កិច្ចអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក |
| USAID/GPL | គម្រោងព្រៃឡង់បៃតង |
| RACHA | អង្គការសម្ព័ន្ធភាពកុមារ និងសុខភាពបន្តពូជ |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិរបស់ប្រទេសជប៉ុន |
| CSOs | អង្គការសង្គមស៊ីវិល |
| STAR-Kampuchea | អង្គការស្តារកម្ពុជា |
| WVI | អង្គការទស្សនពិភពលោក |
| DFAT | នាយកដ្ឋានកិច្ចការបរទេស និងពាណិជ្ជកម្មរបស់ប្រទេសអូស្ត្រាលី |
| OXFAM | អង្គការ OXFAM |
| NCDDS | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| PADD | អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| PMSD | អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| MEID | អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| AFD | អង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុនៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| IAG | ក្រុមសវនកម្មផ្ទៃក្នុងនៃលេខាធិការដ្ឋាន គ.ជ.អ.ប. |
| MOI | ក្រសួងមហាផ្ទៃ |

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MCS | ក្រសួងមុខងារសាធារណៈ |
| MOP | ក្រសួងផែនការ |
| MOWA | ក្រសួងកិច្ចនារី |
| MOEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MOSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ASAC | សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ |
| NACPC | សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត |
| NLC | សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន |
| MOE | ក្រសួងបរិស្ថាន |
| MOH | ក្រសួងសុខាភិបាល |
| MOT | ក្រសួងទេសចរណ៍ |
| MRD | ក្រសួងអភិវឌ្ឍជនបទ |
| MME | ក្រសួងរ៉ែ និងថាមពល |
| MIH | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| MOC | ក្រសួងពាណិជ្ជកម្ម |
| MOWRM | ក្រសួងធនធានទឹក និងឧតុនិយម |
| MLMUPC | ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MCFA | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| MPWT | ក្រសួងសាធារណៈការ និងដឹកជញ្ជូន |
| MLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| LM | ក្រសួង ស្ថាប័នជំនាញ |
| OWSO | ការិយាល័យច្រកចេញចូលតែមួយថ្នាក់ក្រុង ស្រុក ខណ្ឌ |
| CP-OWU | អង្គភាពច្រកចេញចូលតែមួយនៅថ្នាក់រាជធានី ខេត្ត |



Vdo

# វាក្យសព្ទសំខាន់ៗ

| វាក្យសព្ទ | និយមន័យ |
|---|---|
| កជទី១ | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី១ ពីឆ្នាំ២០១០ ដល់ឆ្នាំ២០២០ |
| កជទី២ | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ |
| ផអ៣ | ផែនការអនុវត្តបីឆ្នាំនៃ កជទី១ |
| ផអ៣ទី៣ | ផែនការអនុវត្តរយៈពេលបីឆ្នាំ(២០១៨-២០២០)ដំណាក់កាលទី៣នៃ កជទី១ |
| ផអ៥ទី១ | ផែនការអនុវត្តរយៈពេលប្រាំឆ្នាំ(២០២១-២០២៥)ដំណាក់កាលទី១នៃ កជទី២ |
| ផ.ស.ថ. | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ។ |
| សមិទ្ធផល | ជាឥទ្ធិពលរយៈពេលខ្លីនិងមធ្យម ឬជាការផ្លាស់ប្តូរ ដែលទទួលបាននៅពេលសកម្មភាពមួយ ឬច្រើនត្រូវបានអនុវត្តប្រកបដោយជោគជ័យ។ |
| លទ្ធផល | ផលនៃការងារដែលបានសម្រេច ឬជាផលដែលទទួលបានពីការអនុវត្តសកម្មភាព និងអនុសកម្មភាព។ |
| ចង្កោមសកម្មភាព | ជាក្រុមនៃសកម្មភាពនានា ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក និងត្រូវបានដាក់បញ្ចូល គ្នាជាក្រុម ផ្អែកលើចរិកលក្ខណៈនៃសកម្មភាពទាំងនោះដែលពាក់ព័ន្ធនឹងកិច្ចការចម្បងៗដូចជា ការគ្រប់គ្រងការងារកំណែទម្រង់ អភិបាលកិច្ច ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ការផ្តល់សេវានិងការអភិវឌ្ឍមូលដ្ឋាន និងវិមជ្ឈការហិរញ្ញវត្ថុ ដែលស្របគ្នាជាមួយនឹងសមាសភាគទាំង៥នៃ ផអ៣ទី៣។ |
| សកម្មភាព | ជាការងារចម្បងៗដែលត្រូវសម្រេចនៅចុងបញ្ចប់នៃការអនុវត្ត ផ.ស.ថ. ក្នុងឆ្នាំ នីមួយៗ។ |
| អនុសកម្មភាព | ជាកិច្ចការជាក់លាក់ និងជាអាទិភាពដែលត្រូវអនុវត្ត ឬបំពេញ ដោយប្រើប្រាស់ធនធាន ថវិកា និងជំនួយបច្ចេកទេសនានា ដើម្បីសម្រេចបាននូវការងារចម្បង។ |
| ចំណុចដៅ | ជាកិច្ចការសំខាន់ៗដែលត្រូវសម្រេចក្នុងក្របខ័ណ្ឌពេលវេលាមួយជាក់លាក់ និងមានសូចនាករច្បាស់លាស់ ដើម្បីឈានទៅសម្រេចបាននូវសកម្មភាពជាអាទិភាព។ |

## ១. សេចក្តីផ្តើម

ផែនការសកម្មភាព និងថវិកា (ផ.ស.ថ.) ឆ្នាំ២០២១ របស់ គ.ជ.អ.ប. ជាផែនការឆ្នាំទី១ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០២១-២០៣០ ដំណាក់ កាលទី២ (កជទី២)។ ផែនការនេះត្រូវបានរៀបចំឡើងពីខែឧសភា២០២០ ដល់ខែកុម្ភៈ២០២១ តាមរយៈកិច្ចដំណើរការដែលមានការចូលរួមពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។ កិច្ចដំណើរការនៃការរៀបចំផែនការត្រូវបានពន្យារពេល និង ចំណាយរយៈពេលច្រើនជាងការគ្រោងទុកដោយសារបញ្ហាជំងឺកូវីដ-១៩។ ផ.ស.ថ. ឆ្នាំ២០២១ត្រូវបាន អនុម័តដោយ គ.ជ.អ.ប. នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១។

ស្របជាមួយគោលបំណងនៃ កជទី២, គោលបំណងនៃ ផ.ស.ថ. ឆ្នាំ២០២១ របស់ គ.ជ.អ.ប. គឺ រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង ផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ ខ្លួនកាន់តែមានប្រសិទ្ធភាព។ ដើម្បីសម្រេចបាននូវគោលបំណងនេះ គោលដៅរបស់ ផ.ស.ថ. ឆ្នាំ២០២១ ពង្រឹងរចនាសម្ព័ន្ធ ប្រព័ន្ធ សិទ្ធិអំណាច មុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តអភិបាលកិច្ច ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានជូនប្រជាពលរដ្ឋ។

ផ.ស.ថ. ឆ្នាំ២០២១ របស់ គ.ជ.អ.ប. បែងចែកជា ៥ ចង្កោមសកម្មភាពរួមមាន ការដឹកនាំនិងសម្របសម្រួលការងារកំណែទម្រង់ រចនាសម្ព័ន្ធនិងប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ ការគ្រប់គ្រងនិង ការអភិវឌ្ឍធនធានមនុស្ស វិមជ្ឈការហិរញ្ញវត្ថុនិងប្រព័ន្ធផែនការ និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និង ការផ្តល់សេវានិងការអភិវឌ្ឍមូលដ្ឋាន។ ក្នុងចង្កោមសកម្មភាពទាំង៥ រួមមានសកម្មភាពសរុប ៧១ និងអនុសកម្មភាពចំនួនជាង២០០។ គម្រោងថវិកាចំណាយសរុបមានចំនួន ៣.៦១៧.២៨៣ លានរៀល ស្មើនឹង ៩០៤ លានដុល្លារក្នុងនោះថវិការបស់រាជរដ្ឋាភិបាលមានចំនួន ៣.៤២៧.៣៣៨ លានរៀល ស្មើនឹង ៨៥៧ លានដុល្លារ ថវិកាកម្ចីមានចំនួន ១៤២.២៥៣ លានរៀល ស្មើនឹង ៣៦ លានដុល្លារ និងថវិកាជំនួយ ឥតសំណងគាំទ្រដោយដៃគូអភិវឌ្ឍនានាមានចំនួន ៤៧.៦៩២ លានរៀល ស្មើនឹង ១២ លានដុល្លារ ។

ក្នុងចំណោមសកម្មភាពទាំង ៧១ គ.ជ.អ.ប. បានកំណត់នូវសកម្មភាពជាអាទិភាពចំនួន **៤២** ដែលត្រូវសម្រេចឱ្យបានក្នុងឆ្នាំ២០២១ ក្នុងនោះចង្កោមសកម្មភាពទី១មានសកម្មភាពជាអាទិភាពចំនួន ១៤ ចង្កោមសកម្មភាពទី២មានសកម្មភាពជាអាទិភាពចំនួន ៤ ចង្កោមសកម្មភាពទី៣មានសកម្មភាពជាអាទិភាពចំនួន ៥ ចង្កោមសកម្មភាពទី៤មានសកម្មភាពជាអាទិភាពចំនួន ៩ និងចង្កោមសកម្មភាពទី៥ មានសកម្មភាពជាអាទិភាពចំនួន ១០។ ដោយឡែកសកម្មភាពចំនួន ២៩ ផ្សេងទៀត គឺជាសកម្មភាពដែល មានលក្ខណៈជាការគាំទ្រ និងជាសកម្មភាពដែលពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការរបស់កម្មវិធីទាំងមូល។

ពាក់ព័ន្ធនឹងក្របខ័ណ្ឌពេលវេលានៃការអនុវត្ត សកម្មភាពជាអាទិភាពទាំង ៤២ ត្រូវបានគ្រោងអនុវត្ត និងសម្រេចតាមត្រីមាសដូចខាងក្រោម ៖

- ត្រីមាសទី១ មានចំនួន ០ សកម្មភាព
- ត្រីមាសទី២មានចំនួន ៥ សកម្មភាព

- ត្រីមាសទី៣មានចំនួន ៥ សកម្មភាព និង
- ត្រីមាសទី៤មានចំនួន ៣២ សកម្មភាព។

បើទោះបីជា សកម្មភាពជាអាទិភាពភាគច្រើន ត្រូវបានគ្រោងសម្រេចនៅក្នុងត្រីមាសទី៤ និង ត្រីមាសទី៤ក៏ដោយ ប៉ុន្តែសកម្មភាពជាអាទិភាពទាំងនោះ រួមមានអនុសកម្មភាព ឬចំណុចដៅជាច្រើនដែល ត្រូវចាប់ផ្តើមអនុវត្តពីត្រីមាសទី១ និងត្រីមាសទី២។ ជាមួយគ្នានេះដែរ មានសកម្មភាពជាអាទិភាពមួយ ចំនួនទៀតជាសកម្មភាព ដែលត្រូវអនុវត្តជាទៀងទាត់ប្រចាំខែ ឬប្រចាំត្រីមាសនីមួយៗក្នុងរយៈពេល ពេញមួយឆ្នាំដូចជា ការផ្សព្វផ្សាយព័ត៌មានស្តីពីការងារកំណែទម្រង់ កិច្ចប្រជុំ គ.ជ.អ.ប. កិច្ចប្រជុំប្រចាំខែ របស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ ក្រោមជាតិ កិច្ចប្រជុំប្រចាំខែរបស់ គ.ក.ស.ក. កិច្ចប្រជុំប្រចាំខែរបស់ការិយាល័យប្រជាពលរដ្ឋ និង សកម្មភាពនានានៃការអភិវឌ្ឍសមត្ថភាពជាដើម។

សកម្មភាពជាអាទិភាពទាំង៤២ រួមមានអនុសកម្មភាព ឬចំណុចដៅចំនួន១៧៩ ដែលត្រូវអនុវត្តដើម្បីសម្រេចបាននូវសកម្មភាពជាអាទិភាពទាំងនោះ។ ក្របខ័ណ្ឌពេលវេលានៃការអនុវត្តអនុសកម្មភាព ឬចំណុចដៅដែលត្រូវសម្រេចតាមត្រីមាសនីមួយៗមានបង្ហាញក្នុងតារាងទី១ខាងក្រោម។

**តារាងទី១ ៖ ចំណុចដៅ និងក្របខ័ណ្ឌពេលវេលាអនុវត្ត**

| ចង្កោមសកម្មភាព | សកម្មភាពជាអាទិភាព | ចំណុចដៅដែលត្រូវសម្រេច | ចំណុចដៅត្រូវសម្រេចតាមត្រីមាស | | | |
|---|---|---|---|---|---|---|
| | | | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ |
| ១ | ១៤ | **៦៨** | ១៣ | ២០ | ២០ | ១៥ |
| ២ | ៤ | **១៥** | ១ | ២ | ៥ | ៧ |
| ៣ | ៥ | **៣១** | ៣ | ៩ | ៨ | ១១ |
| ៤ | ៩ | **១៦** | ២ | ២ | ៤ | ៨ |
| ៥ | ១០ | **៤៩** | ១៣ | ១៤ | ៩ | ១៣ |
| **សរុប** | **៤២** | **១៧៩** | **៣២** | **៤៦** | **៤៧** | **៥៤** |

វឌ្ឍនភាពសង្ខេបនៃការអនុវត្តសកម្មភាពជាអាទិភាពទាំង៤២ មានរៀបរាប់នៅក្នុងផ្នែកទី២ ដោយឡែកវឌ្ឍនភាពលម្អិតនៃការអនុវត្តសកម្មភាពជាអាទិភាពនីមួយៗ មានបរិយាយក្នុងឧបសម្ព័ន្ធទី១ និងវឌ្ឍនភាពនៃការអនុវត្តសកម្មភាពធៀបនឹងសូចនាករឆ្នាំ២០២១ គិតត្រឹមចុងឆមាសទី១មានបរិយាយក្នុងឧបសម្ព័ន្ធទី២ នៃរបាយការណ៍នេះ។

របាយការណ៍វឌ្ឍនភាពនេះរៀបរាប់អំពីស្ថានភាពនៃការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២១ របស់ គ.ជ.អ.ប. ក្នុងរយៈពេល១២ ខែគិតពីខែមករាដល់ខែធ្នូ ឆ្នាំ២០២១ រួមមានស្ថានភាពនៃការអនុវត្ត សកម្មភាព ស្ថានភាពនៃការអនុវត្តថវិកា និងបញ្ហាប្រឈមនានាដែលបាន និងកំពុងជួបប្រទះ ព្រមទាំង សំណើវិធានការដោះស្រាយនានាចំពោះបញ្ហាប្រឈមទាំងនោះ។

## ២. សេចក្តីសង្ខេបអំពីវឌ្ឍនភាព

ក្នុងឆ្នាំ២០២១ ការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២១របស់ គ.ជ.អ.ប. សម្រេចបានលទ្ធផល៧៦% ពោលគឺក្នុងចំណោមសកម្មភាពជាអាទិភាពចំនួន៤២ដែលបានគ្រោង មានសកម្មភាពជាអាទិភាពចំនួន៣២បានអនុវត្ត ក្នុងនោះសកម្មភាពចំនួន១១បានអនុវត្តចប់ និងសម្រេចបានលទ្ធផល១០០% និងសកម្មភាពចំនួន២១ បាន និងកំពុងដំណើរការអនុវត្ត។ ដោយឡែក សកម្មភាពជាអាទិភាពចំនួន១០ ពុំទាន់បានចាប់ផ្តើមអនុវត្តនៅឡើយ។ ជាមួយគ្នានេះដែរ ការអនុវត្តចំណុចដៅទាំង១៧៩នៃសកម្មភាព ជាអាទិភាពទាំង៤២សម្រេចបានលទ្ធផលចំនួន៧៩% ពោលគឺក្នុងចំណោមចំណុចដៅទាំង១៧៩នេះ មានចំណុចដៅចំនួន១៤១បានអនុវត្ត ក្នុងនោះចំណុចដៅចំនួន៨៤បានអនុវត្តចប់ និងសម្រេចបាន លទ្ធផល ១០០% និងចំណុចដៅចំនួន៥៧ បាននិងកំពុងដំណើរការអនុវត្ត។ ដោយឡែក ចំណុចដៅ ចំនួន៣៨ពុំទាន់បានចាប់ផ្តើមអនុវត្តនៅឡើយ។

សមិទ្ធផលសំខាន់ៗនៃសកម្មភាពជាអាទិភាព និងអនុសកម្មភាព ឬចំណុចដៅដែលបានអនុវត្តចប់១០០% និងកំពុងដំណើរការអនុវត្តមានសង្ខេបតាមចង្កោមសកម្មភាពដូចខាងក្រោម ៖

**១. ចង្កោមសកម្មភាពទី១ស្តីពីការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់ សម្រេចបាន នូវលទ្ធផលសំខាន់ៗដូចខាងក្រោម ៖**

- ឯកសារកម្មវិធីជាតិដំណាក់កាលទី២ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ (កជទី២) ត្រូវបានរៀបចំតាក់តែងដោយមានជំនួយបច្ចេកទេសពីក្រុមទីប្រឹក្សាដែលគាំទ្រដោយ EU, SDC និង GIZ និងបានអនុម័តដោយរាជរដ្ឋាភិបាលនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១។
- សេចក្តីព្រាងផែនការអនុវត្តរយៈពេលប្រាំឆ្នាំលើកទី១ ពីឆ្នាំ២០២១ដល់ឆ្នាំ២០២៥នៃ កជទី២ (ផអ៥ទី១) ត្រូវបានរៀបចំ
- កិច្ចប្រជុំរបស់ គ.ជ.អ.ប. លើកទី១៩ ត្រូវបានរៀបចំនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ដែលផ្តោតជាសំខាន់លើការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងឯកសារ កជទី២
- ផែនការសកម្មភាព និងថវិកាឆ្នាំ២០២១របស់ គ.ជ.អ.ប. ត្រូវបានអនុវត្តដោយ គ.ជ.អ.ប. នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២១។
- សេចក្តីសម្រេចរួមឆ្នាំ២០២១រវាង គ.អ.អ.ប. ជាមួយក្រសួង ស្ថាប័ន និងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងអនុម័ត
- របាយការណ៍ប្រចាំឆ្នាំ២០២០ស្តីពីការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២០ របស់ គ.ជ.អ.ប. ត្រូវបានរៀបចំ និងអនុម័តនៅខែមីនា ២០២១ និងបានដាក់ជូន គ.ជ.អ.ប. ក្រសួង ស្ថាប័ន រដ្ឋបាល ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធនានា
- របាយការណ៍ JMI ឆ្នាំ២០២០ និងផែនការ JIM ឆ្នាំ២០២១-២០២៣ ត្រូវបានរៀបចំ និង អនុម័តដោយប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. និងអ្នកសម្របសម្រួលដៃគូអភិវឌ្ឍ និងបាន ផ្ញើជូន CDC

- សេចក្តីព្រាងនៃ ផ.ស.ថ. ឆ្នាំ២០២២របស់ គ.ជ.អ.ប. បានរៀបចំ
- គ.ជ.វ.វ. របស់ក្រសួង ស្ថាប័ន និងរបស់រាជធានី ខេត្ត និងក្រុង ស្រុកមួយចំនួនបានរៀបចំ កិច្ចប្រជុំរបស់ខ្លួន ដើម្បីពិនិត្យមើលវឌ្ឍនភាព និងបញ្ហាប្រឈមនៃការរៀបចំ និងការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២១របស់ខ្លួន
- ថ្នាក់ដឹកនាំនៃសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋានបានរៀបចំកិច្ចប្រជុំរបស់ខ្លួនក្នុងអំឡុងខែមករា-កុម្ភៈ ដើម្បីពិនិត្យ និងអនុម័តផែនការឆ្នាំ២០២១ រួមបញ្ចូលទាំងកម្មវិធីបណ្តុះបណ្តាលនានាសម្រាប់សមាជិករបស់ខ្លួន និងអ្នកពាក់ព័ន្ធនានា
- កិច្ចប្រជុំប្រចាំឆ្នាំរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋានត្រូវបានរៀបចំ ដើម្បីពិនិត្យ និងអនុម័តលើរបាយការណ៍ការងារប្រចាំឆ្នាំ២០២០ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០២១
- សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋានបានពិនិត្យ និងកែសម្រួលក្រមសីលធម៌ និងនីតិវិធីគ្រប់គ្រង និងប្រតិបត្តិការរបស់ខ្លួន
- សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានមួយចំនួនបានរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការការងារឆ្នាំ២០២១របស់ខ្លួន
- បានផលិតសារខ្លីៗ Info-graphics banners ដើម្បីផ្សព្វផ្សាយទៅកាន់អ្នកពាក់ព័ន្ធ និងសាធា រណៈជន តាម រយៈគេហទំព័រ និងបណ្តាញសង្គមរបស់ គ.ជ.អ.ប.។
- បានធ្វើការផ្សព្វផ្សាយកម្មវិធីស្មាតហ្វូន I-SAF ដើម្បីឱ្យមានអ្នកទាញយកមកប្រើប្រាស់កាន់តែច្រើនឡើងទាំងនៅលើ iOS និង Android។
- បានបង្កើត និងដាក់ឱ្យអនុវត្តនូវ I-SAF Telegram Channel នៅខែមិថុនា ឆ្នាំ២០២១ ដែលមានឈ្មោះថា « គណនេយ្យភាពសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ/ I-SAF For SNAs » ដើម្បីបង្កើនការផ្សព្វផ្សាយ អំពីផែនការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម។
- បានចុះអនុស្សារណៈយោគយល់គ្នារវាងលេខាធិការដ្ឋាន គ.ជ.អ.ប ជាមួយអង្គការ Internew Network ប្រចាំនៅកម្ពុជានៅខែមេសា ឆ្នាំ២០២១ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង និងផ្សព្វផ្សាយព័ត៌មាននៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២។
- គោលនយោបាយ និងលិខិតបទដ្ឋាននានាស្តីពីកំណែទម្រង់នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងផ្សព្វផ្សាយនៅលើគេហទំព័រ និងបណ្តាញព័ត៌មានសង្គមរបស់ គ.ជ.អ.ប.
- សៀវភៅណែនាំស្តីពីការគ្រប់គ្រងគម្រោង (Project Management Manual) ត្រូវបានរៀបចំ និងអនុម័ត ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១
- គម្រោងគាំទ្រលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការបំពេញល័ក្ខខ័ណ្ឌនានារបស់ GCF ត្រូវបានអនុវត្ត ក្នុងខែធ្នូ ឆ្នាំ២០២០ និងកំពុងដំណើរអនុវត្ត ដោយបានបង្កើតក្រុមការងារ និងគណៈកម្មការ

នានា និងការជ្រើសរើសទីប្រឹក្សា....ដើម្បីអនុវត្ត និងគ្រប់គ្រងគម្រោង

- ឯកសារទស្សនទាននៃគម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុដំណាក់កាលទី៣ បានរៀបចំ និងដាក់ជូន GCF
- កម្មវិធីការងាររយៈ៥ឆ្នាំ (២០២១-២០២៥) របស់លេខាធិការដ្ឋាន គ.ជ.អ.ប. ស្តីពីគម្រោង អាទិភាពនៃការប្រែប្រួលអាកាសធាតុ បានរៀបចំ និងអនុម័ត
- សវនកម្មលើផែនការមេ និងផែនការអនុវត្តសកម្មភាពជាអាទិភាពនានារបស់លលេខាធិការដ្ឋាន ក្នុងការបំពេញក្នុងការបំពេញល័ក្ខខ័ណ្ឌនានារបស់ GCF ត្រូវបានអនុវត្តបញ្ចប់
- ឯកសារទស្សនទានចំនួន២ពាក់ព័ន្ធនឹងការធ្វើកសិកម្មតាមបែបធម្មជាតិ និងការគ្រប់គ្រងទឹកស្អាត និងអនាម័យដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំ
- សេចក្តីព្រាងសំណើគម្រោងចំនួន២ ដែលពាក់ព័ន្ធនឹងការរៀបចំក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងដើម្បីគាំទ្រដល់ការរៀបចំសំណើគម្រោងចំនួន២ស្តីពីទីក្រុងដែលមានភាពធន់ និងមធ្យោបាយដឹកជញ្ជូនដែលមានជាតិកាបូនទាបត្រូវបានរៀបចំ។

**២. ចង្កោមសកម្មភាពស្តីពីរចនាសម្ព័ន្ធ និងប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ** សម្រេចបាននូវលទ្ធផលសំខាន់ៗដូចខាងក្រោម ៖

- យុទ្ធសាស្ត្រស្តីពីរចនាសម្ព័ន្ធ មុខងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការរៀបចំតាក់តែងសមាសភាគទី២ និងសមាសភាគ ទី៥នៃ កជទី២
- សមាសភាព និងតួនាទី ភារកិច្ចរបស់គណៈគ្រប់គ្រង ISAF ត្រូវពិនិត្យ និងកែសម្រួល
- កិច្ចប្រជុំលើកទី៦របស់គណៈគ្រប់គ្រង ISAF ត្រូវបានរៀបចំរួមបញ្ចូលទាំងសិក្ខាសាលាចាប់ផ្តើមគម្រោងគាំទ្រ ISAF ដំណាក់កាលទី២ (២០១៩-២០២៣)
- ផ្ទាំងព័ត៌មានសម្រាប់ប្រជាពលរដ្ឋ I4C ត្រូវបានពិនិត្យ និងកែសម្រួលដោយមានការប្រឹក្សាយោ បល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ក្រុមការងារ ISAF ថ្នាក់ខេត្ត និងក្រុង ស្រុកក្នុងតំបន់គោលដៅថ្មីចំនួន៣ខេត្ត និងក្រុង ស្រុក ចំនួន២៨ ត្រូវបានបង្កើត
- វគ្គបណ្តុះបណ្តាលដល់មន្ត្រីបង្គោលគណនេយ្យភាពសង្គមថ្នាក់ខេត្ត ក្រុង ស្រុកគោលដៅថ្មី ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមចំនួន ៤វគ្គ ដែលមានការចូលរួមពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តកែប និងរដ្ឋបាលក្រុង ស្រុកចំនួន២៧ ត្រូវបានរៀបចំ
- វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមដល់មន្ត្រីបង្គោលគណនេយ្យភាពសង្គមថ្នាក់ខេត្ត ក្រុង ស្រុកគោលដៅចាស់ចំនួន២វគ្គ ដល់ខេត្តចំនួន១១ និងក្រុង ស្រុកគោលដៅចំនួន១០ ត្រូវបានរៀបចំ និងសហការសម្របសម្រួល
- ទិន្នន័យព័ត៌មានស្តីពីលទ្ធផលការងារនៃភ្នាក់ងារផ្តល់សេវាទាំង៣ដែលរួមមាន រដ្ឋបាលឃុំ សង្កាត់

សាលាបឋមសិក្សា និងមណ្ឌលសុខភាពត្រូវបានបញ្ចូលក្នុងប្រព័ន្ធទិន្នន័យ ដោយសម្រេចបានចំនួន៨៤,៤៨% គិតត្រឹមខែធ្នូ ឆ្នាំ២០២១

- នាយកដ្ឋានមុខងារ និងធនធាន ក្រសួងមហាផ្ទៃបានសហការជាមួយ DAR/GIZ និងអង្គការ តម្លាភាពអន្តរជាតិក្នុងការរៀបចំសិក្ខាសាលាប្រចាំឆ្នាំស្តីពីការពង្រឹងយន្តការបណ្តឹងមូលដ្ឋាន ដោយ មានមន្ត្រីការិយាល័យប្រជាពលរដ្ឋចូលរួមចំនួន១១៥នាក់
- ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តទាំង២៥ទទួលបានពាក្យបណ្តឹងស្ថិតក្នុងសមត្ថកិច្ចចំនួន ៨៨៦បណ្តឹង ដែលក្នុងនោះបណ្តឹងដែលដោះស្រាយបានរួចរាល់មានចំនួន៧៧៨ ស្មើនឹង៨៨% និងកំពុងបន្តដោះស្រាយមានចំនួន១០៨ករណី។ វគ្គបណ្តុះបណ្តាលអំពីនីតិវិធីស៊ើបអង្កេតបណ្តឹងត្រូវបានរៀបចំដល់ប្រធានការិយាល័យប្រជាពលរដ្ឋទាំង២៥។
- ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌចំនួន១២០ទទួលបានពបណ្តឹងក្នុងសមត្ថកិច្ចចំនួន ៣០៥ករណី ក្នុងនោះបណ្តឹងចំនួន២៩៦ករណី ស្មើនឹង៩៧%បានដោះស្រាយរួចរាល់ និងបណ្តឹងចំនួន០៩ ករណីកំពុងដំណើរការដោះស្រាយ។ វគ្គបណ្តុះបណ្តាលអំពីការសម្រុះសម្រួលដោះស្រាយបណ្តឹងបានរៀបចំដល់ប្រធានការិយាល័យប្រជាពលរដ្ឋទាំង១២០។
- ប្រព័ន្ធទិន្នន័យមូលដ្ឋានគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក ខណ្ឌកំពុងដំណើរការពិនិត្យ និងកែសម្រួលដើម្បីរៀបចំជាប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់ការគ្រប់គ្រង (MIS)។

**៣. ចង្កោមសកម្មភាពទី៣ស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ** សម្រេចបាននូវលទ្ធផលសំខាន់ៗដូចខាងក្រោម ៖

- បានប្រមូល និងរៀបចំបញ្ចប់នូវទិន្នន័យដើមគ្រាអំពីបុគ្គលិកវិស័យដែលបានផ្ទេរទៅឱ្យរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌសម្រាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើសមាហរណកម្មបុគ្គលិកទាំងនោះទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្របតាមអនុក្រឹត្យលេខ១៩២ ១៨២ ១៨៣ និង១៨៤
- បានរៀបចំបញ្ជីសមាហរណកម្មរចនាសម្ព័ន្ធ និងក្របខ័ណ្ឌបុគ្គលិកវិស័យដែលបានផ្ទេរទៅឱ្យរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌក្នុងបញ្ជីប្រាក់បៀវត្សរបស់រដ្ឋបាលទាំងនោះ
- ក្រសួងមុខងារសាធារណៈ សហការជាមួយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំសេចក្តីព្រាងការបរិយាយអំពីមុខតំណែង និងលក្ខខណ្ឌការងាររបស់បុគ្គលិកក្រុង ស្រុកចំនួន៥៣មុខតំណែង និងបានពិនិត្យ និងកែសម្រួលគោលការណ៍ បែបបទ និងនីតិវិធីសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមអនុក្រឹត្យលេខ១៨២ ១៨៣ និង១៨៤
- សេចក្តីព្រាងសេចក្តីណែនាំស្តីពីការគ្រប់គ្រងបុគ្គលិកផ្អែកលើសមិទ្ធកម្ម ត្រូវបានរៀបចំដោយក្រសួងមុខងារសាធារណៈ
- សាលាជាតិរដ្ឋបាលមូលដ្ឋានបានសម្របសម្រួល និងរៀបចំវគ្គបណ្តុះបណ្តាលដោយទទួលបាននូវលទ្ធផលសំខាន់ៗដូចខាងក្រោម ៖



Vdy

- សហការជាមួយ JICA រៀបចំវគ្គគ្រូឧទ្ទេសដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានសិក្ខាកាមចូលរួមចំនួន១៣នាក់ក្នុងនោះមានស្ត្រីចំនួន៩នាក់
- សហការជាមួយ WATERAID ក្នុងការរៀបចំវគ្គគ្រូឧទ្ទេសរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌចំនួន៨ វគ្គអំពីភាពជាអ្នកដឹកនាំ នៅខេត្តបាត់ដំបង ប៉ៃលិន ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ចាម កំពង់ធំ កំពង់ស្ពឺ និងតាកែវ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន២៧៤នាក់ ក្នុងនោះមានស្ត្រីចំនួន៥៨នាក់
- សហការជាមួយ UNDP ក្នុងការរៀបចំគ្រូឧទ្ទេសអំពីនវានុវត្តន៍ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន១០នាក់ក្នុងនោះស្ត្រីមានចំនួន៣នាក់
- សហការជាមួយ DAR/GIZ ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលអំពីមុខងារគ្រប់គ្រង និងការផ្តល់សេវាសុខាភិបាលរួមបញ្ចូលទាំងការគ្រប់គ្រងកូវីដ-១៩ដល់ក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត មន្ទីរសុខាភិបាល និងថ្នាក់ដឹកនាំមន្ទីរពេទ្យបង្អែកនៃខេត្តបាត់ដំបង កំពត កែប និងកំពង់ធំ។ ជាមួយគ្នានេះដែរ ក៏បានរៀបចំសេចក្តីណែនាំបច្ចេកទេស និងសម្ភារៈបណ្តុះបណ្តាលសម្រាប់ការអនុវត្តមុខងារវិស័យអប់រំដែលបានផ្ទេរទៅឱ្យក្រុង ស្រុក។

- កិច្ចដំណើរការនៃការសាងសង់អគារសាលាជាតិរដ្ឋបាលមូលដ្ឋានមានវឌ្ឍនភាពដូចខាងក្រោម ៖
  - បានរៀបចំគណៈគ្រប់គ្រងសាលាជាតិរដ្ឋបាលមូលដ្ឋាន
  - បានរៀបចំអង្គភាពគ្រប់គ្រងគម្រោងសាងសង់សាលាជាតិ
  - បានបង្កើតគណៈកម្មការត្រួតពិនិត្យ និងអនុម័យលទ្ធកម្ម និងគណៈកម្មការវាយតម្លៃ ឯកសារលទ្ធកម្មគម្រោង
  - បានជ្រើសរើសក្រុមទីប្រឹក្សាគម្រោងសាងសង់សាលាជាតិដែលមានសមាជិកចំនួន៦នាក់
  - កំពុងដំណើរការជ្រើសរើសក្រុមហ៊ុនសម្រាប់រៀបចំប្លង់ និងត្រួតពិនិត្យការសាងសង់។
- រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំ និងអនុវត្តសកម្មភាពវគ្គបណ្តុះបណ្តាល និងការផ្សព្វផ្សាយអភិវឌ្ឍសមត្ថភាពចំនួនជាង៥០០សកម្មភាពដល់សិក្ខាកាមចំនួន១០.១៨០នាក់ ដែលពាក់ព័ន្ធជាមួយប្រធានបទសំខាន់ៗដូចខាងក្រោម ៖
  - ការរៀបចំតាក់តែងលិខិតបទដ្ឋាននានា
  - ច្បាប់គ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០២១
  - គោលការណ៍ បែបបទ និងនីតិវិធីគ្រប់គ្រងបុគ្គលិកតាមបែបវិមជ្ឈការ
  - កិច្ចការរដ្ឋបាល
  - វគ្គគ្រូឧទ្ទេសថ្នាក់ក្រុង ស្រុក ខណ្ឌអំពីការងារគណនេយ្យភាពសង្គម
  - ការជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរបស់ឃុំ សង្កាត់
  - ការរៀបចំកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងសេចក្តីណែនាំបន្ថែមលេខ១៤៩
  - ការបញ្ចូលទិន្នន័យគម្រោងអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់លក្រោមជាតិ



Vdo

- ការរៀបចំ និងការប្រព្រឹត្តទៅរបស់ គ.ក.ន.ក.
- ការអនុវត្តការងារសេវាសង្គមនៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ
- កិច្ចដំណើរការកសាងផែនការ រួមបញ្ចូលទាំងឧបករណ៍កសាងផែនការ និងការគ្រប់គ្រងប្រព័ន្ធទិន្នន័យមូលដ្ឋាន
- វគ្គរំលឹកឡើងវិញអំពីសុវត្ថិភាពបរិស្ថាន និងសង្គម
- ការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- នីតិវិធីសម្រុះសម្រួលដោះស្រាយបណ្តឹង
- ផែនការអនុវត្តស្តីពីការបង្កើនចំនួនបុគ្គលិកជាស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ជំនាញវិស័យសម្រាប់បុគ្គលិក្រុង ស្រុក ខណ្ឌ។ល។

- បានរៀបចំសម្ភារៈសម្រាប់វគ្គបណ្តុះបណ្តាលអំពីជំនាញភាពជាអ្នកដឹកនាំសម្រាប់បុគ្គលិកជាស្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសក្តានុពលសម្រាប់មុខតំណែងគ្រប់គ្រង
- បានរៀបចំយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំសមាសភាគទី៣នៃ កជទី២
- បានរៀបចំយុទ្ធសាស្ត្រស្តីពីសមភាពយេនឌ័រ និងការងាបរិយាប័ន្ននិងសមធម៌សង្គម និងបាន បញ្ជ្រាបចូលក្នុងសេចក្តីព្រាងឯកសារ កជទី២។

**៤. ចង្កោមសកម្មភាពទី៤ស្តីពីវិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធកសាងផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** សម្រេចបាននូវលទ្ធផលសំខាន់ៗដូចខាងក្រោមរួមមាន ៖

- បានរៀបចំយុទ្ធសាស្ត្រស្តីពីវិមជ្ឈការហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំសមាសភាគទី៤នៃ កជទី២
- មូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌសម្រាប់វិស័យសុខាភិបាលត្រូវបានវិភាជ និងផ្ទេរទៅឱ្យរាជធានី ខេត្តទាំង២៥ និងសម្រាប់វិស័យអប់រំត្រូវបានវិភាជ និងផ្ទេរទៅឱ្យក្រុង ស្រុក ខណ្ឌទាំង២០៣ ដែលមានទឹកប្រាក់សរុបចំនួនជាង ៨២៤.០០០ លានរៀល
- ថវិកាឧបត្ថម្ភធនសម្រាប់ការិយាល័យជំនាញនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំង២០៣ ត្រូវបាន វិភាជ និងផ្ទេរទៅឱ្យរដ្ឋបាលទាំងនោះដែលមានថវិកាសរុបចំនួនជាង ១៣១.០០០លានរៀល
- សំណើគម្រោងស្តីពីការគាំទ្រលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការបំពេញល័ក្ខខ័ណ្ឌរបស់ GCF ត្រូវបានអនុម័ត និងអនុវត្ត ដែលមានរយៈពេល២៤ខែ និងថវិកាសរុបចំនួន៥១៧.០០០ដុល្លារ
- រដ្ឋបាលក្រុង ស្រុក ខណ្ឌទាំង២០៣បានអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុថ្មី ស្របតាមរចនាសម្ព័ន្ធ និងមុខងាររបស់ខ្លួនដែលបានកែសម្រួល ស្របតាមអនុក្រឹត្យលេខ១៨២ ១៨៣ និង១៨៤។
- ពាក់ព័ន្ធនឹងមូលនិធិ SNIF (គាំទ្រដោយ ADB), បានអនុវត្តគម្រោងគម្រោងវិនិយោគសាងសង់ក្នុងស្រុកចំនួន២២ និងបានបញ្ចប់១០០%។

- គម្រោងគាំទ្រដោយមូលនិធិ SNIF ចំនួន៥០ ក្នុងស្រុកគោលដៅថ្មីចំនួន៥០ ត្រូវបានរៀបចំ និងអនុវត្ត។
- ក្រសួងផែនការបានរៀបចំវគ្គរំលឹកឡើងវិញដល់មន្ត្រីមន្ទីរផែនការរាជធានី ខេត្តទាំង២៥ស្តីពីការកែច្នៃទិន្នន័យ ការរៀបចំព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ចនិងសង្គមកិច្ច និងតារាងពិន្ទុវិស័យ និងទំនាក់ទំនងនៃការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ជាមួយនឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។

**៥. ចង្កោមសកម្មភាពទី៥ស្តីពីការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន** សម្រេចបាននូវលទ្ធផល សំខាន់ៗដូចខាងក្រោមរួមមាន រួមមាន ៖

- ក្រសួង ស្ថាប័នចំនួន២០បាន និងកំពុងដំណើរការរៀបចំសេចក្តីណែនាំ និងឯកសារបច្ចេកទេសស្តីពីការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យក្រុង ស្រុក ខណ្ឌក្នុងនោះក្រសួងចំនួន១៤បានបញ្ចប់ការរៀបចំសេចក្តីណែនាំនេះ និងក្រសួងចំនួន០៦កំពុងដំណើរការរៀបចំ។ ជាមួយគ្នានេះដែរក្រសួងមួយចំនួនក៏បានអនុវត្ត និងសម្រេចបាននូវលទ្ធផលសំខាន់ៗបន្ថែមដូចខាងក្រោម ៖
    - ក្រសួងអប់រំកំពុងរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីការគ្រប់គ្រងការងារអប់រំ យុវជន និងកីឡា និងបានរៀបចំកិច្ចប្រជុំ គ.ជ.វ.វ. បានចំនួន២លើក
    - ក្រសួងទេសចរណ៍បានរៀបចំសិក្ខាសាលាជាមួយមន្ទីរទេសចរណ៍រាជធានី ខេត្តក្នុងខែឧសភាអំពីសេចក្តីណែនាំស្តីពីការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យក្រុង ស្រុក ខណ្ឌ
    - ក្រសួងសាធារណៈការ និងដឹកជញ្ជូនសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. រៀបចំកិច្ចប្រជុំស្តីពីការបែងចែកចំណូលទទួលបានថ្លៃឈ្នួលសេវាសាធារណៈការ និងបានសហការជាមួយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការរៀបចំសិក្ខាសាលាចំនួន៣លើកជាមួយរាជធានី ខេត្តទាំង២៥ ដើម្បីផ្សព្វផ្សាយអំពីបែបបទ និងនីតិវិធីសម្រាប់ផ្តល់សេវារដ្ឋបាលក្នុងវិស័យសាធារណៈការ ដែលមានសិក្ខាកាមចូលរួមចំនួន២២០នាក់ក្នុងនោះមានស្ត្រីចំនួន៦១នាក់
    - ក្រសួងកសិកម្មបានបរៀបចំ និងពិភាក្សាអំពីប្រកាសស្តីពីបែបបទ នីតិវិធី និងល័ក្ខខ័ណ្ឌសម្រាប់ការផ្តល់សេវារដ្ឋបាលក្នុងវិស័យកសិកម្មនៅអង្គភាពសេវាច្រកចេញចូលតែមួយរាជធានី ខេត្ត។
- ក្រសួងមុខងារសាធារណៈសហការជាមួយ DAR/GIZ កំពុងរៀបចំសេចក្តីណែនាំស្តីពីការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចដំណើរការផ្តល់សេវាសាធារណៈ និងបានរៀបចំចងក្រងមេរៀនបទពិសោធន៍ ក៏ដូចជាការផលិតវីដេអូអំពីគំរូល្អនៃអង្គភាពផ្តល់សេវាសាធារណៈក្នុង វិស័យសុខាភិបាល និវិស័យអប់រំ
- ក្រសួងអប់រំបានសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. និង DAR/GIZ ក្នុងការសិក្សាអំពីទិន្នន័យដើមគ្រា និងធ្វើការអង្កេតអំពីស្ថានភាពនៃមុខងារអប់រំដែលបានផ្ទេរ



Vde

- នាយកដ្ឋានមុខងារ និងធនធាន ក្រសួងមហាផ្ទៃសហការជាមួយ DAR/GIZ ក្នុងការ ៖
  - ពិនិត្យ និងកែសម្រួលប្រកាស និងសេចក្តីណែនាំនានាអំពីគោលការណ៍ និងនីតិវិធីសម្រាប់ការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ និងបានរៀបចំវគ្គគ្រូឧទ្ទេសអំពីឯកសារទាំងនេះដល់មន្រ្តីនាយកដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន២០នាក់ក្នុងនោះមានស្រ្តីចំនួន៧នាក់ ពីថ្ងៃទី២១-២៣ ខែមេសា
  - រៀបចំសិក្ខាសាលាផ្សព្វផ្សាយដល់ថ្នាក់គ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ (អភិបាល និងនាយករដ្ឋបាល) នៃក្រុង ស្រុក ខណ្ឌទាំង២០៣អំពីគោលការណ៍ និងនីតិវិធីសម្រាប់ ការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌពីថ្ងៃទី១៤-១៥ ខែ មិថុនា ២០២១
  - រៀបចំសិក្ខាសាលាប្រចាំឆ្នាំអំពីការពង្រឹងយន្តការបណ្តឹងមូលដ្ឋាន ដើម្បីកំណត់បញ្ហាប្រឈម ដំណោះស្រាយ និងអនុសាសន៍នានាសម្រាប់ការលើកកម្ពស់ប្រសិទ្ធភាពការងាររបស់មន្ត្រីការិយាល័យប្រជាពលរដ្ឋ ដែលមានអ្នកចូលរួមសរុបចំនួន១១៥នាក់។
- ជាមួយគ្នានេះដែរ យន្តការនៃការិយាល័យសេវាច្រកចេញចូលតែមួយក៏បានសម្រេចលទ្ធផលមួយចំនួនទៀតដូចខាងក្រោម ៖
  - បានរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីសម្រាប់ផ្តល់សេវានៅតាមយន្តការច្រកចេញចូលតែមួយថ្នាក់ឃុំ សង្កាត់
  - បានរៀបចំប្រកាសអន្តរក្រសួងស្តីពីបែបបទ បច្ចេកទេស និងនីតិវិធីសម្រាប់ការផ្តល់សេវារដ្ឋបាលក្នុងវិស័យកសិកម្មនៅថ្នាក់រាជធានី ខេត្ត
  - បានរៀបចំវគ្គគ្រូឧទ្ទេសស្តីពីគោលការណ៍ និងនីតិវិធីសម្រាប់ការផ្តល់សេវារដ្ឋបាលតាម រយៈការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ
  - ប្រកាស និងសេចក្តីណែនាំនានាអំពីគោលការណ៍ និងនីតិវិធីសម្រាប់ផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌពិនិត្យ និងកែសម្រួលស្របតាម អនុក្រឹត្យលេខ១៨២ ១៨៣ និង១៨៤ ស្តីពី រចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបានផ្សព្វផ្សាយ ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។
  - បានរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីសម្រាប់ផ្តល់សេវានៅតាមយន្តការច្រកចេញចូលតែមួយថ្នាក់ឃុំ សង្កាត់។
  - អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តទាំង២៥ បានផ្តល់សេវារដ្ឋបាលសរុបចំនួន ៤៤២.១០៨ និងទទួលបានចំណូលសរុបចំនួន៨៦.០១៨.៥៧៦.០៨២រៀល (ស្មើនឹង ២១.៥០៤.៦៤៤,០២០ដុល្លារអាមេរិក)
  - ការិយាល័យផ្តល់សេវាច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌចំនួន១១៥ការិយាល័យបានផ្តល់សេវារដ្ឋបាលសរុបចំនួន១,៧៥០,៨៦៩សេវា និងទទួលបានចំណូលសរុបចំនួន ១៥.៣២៧.២០២.២៨៥រៀល (ស្មើនឹង៣.៨៣១.៨០០,៥៧១ដុល្លារអាមេរិក)។



Vda

- បានរៀបចំចងក្រងជាឯកសារនូវមេរៀនបទពិសោធន៍ល្អៗស្តីពីការអនុវត្តមុខងារជាអាណត្តិទូទៅសម្រាប់ផ្សព្វផ្សាយ
- បានរៀបចំសេចក្តីព្រាងយុទ្ធសាស្រ្តស្តីពីការកាត់បន្ថយភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងបានបញ្ជ្រាបការងារនេះទៅក្នុងឯកសារកម្មវិធីជាតិដំណាក់កាលទី២
- សេចក្តីណែនាំសម្រាប់ការសាកល្បងបញ្ជ្រាបគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម និងគោលនយោបាយសមភាពយេនឌ័រក្នុងការអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំដោយមានជំនួយបច្ចេកទេសពិទីប្រឹក្សាគាំទ្រដោយ UNCDF។

ចង្កោមសកម្មភាពនេះ ក៏រួមបញ្ចូលផងដែរនូវសកម្មភាពរបស់គម្រោង កម្មវិធីជាច់ដោយឡែកមួយចំនួនរបស់ដៃគូអភិវឌ្ឍដែលសម្របសម្រួលដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងសេវាមូលដ្ឋាន ការលើកកម្ពស់ភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការលើកកម្ពស់ស្បៀងនិងអាហារូបត្ថម្ភ ការលើកកម្ពស់សេវាសង្គម ការលើកកម្ពស់សង្គមកិច្ច សេដ្ឋកិច្ច និងជីវភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ល។

វឌ្ឍនភាពនៃការអនុវត្តគម្រោង កម្មវិធីទាំងនេះក្នុងឆ្នាំ២០២១មានសង្ខេបដូចខាងក្រោម ៖

✓ <u>**គម្រោងការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍកសិកម្មខ្នាតតូច ដំហានទី២** (TSSD-AF)</u> ៖

គម្រោងនេះមានរយៈពេល៥ឆ្នាំ ដោយចាប់ផ្តើមអនុវត្តពីត្រីមាសទី១ឆ្នាំ២០១៨ដល់ត្រីមាសទី១ឆ្នាំ២០២៣ និងអនុវត្តក្នុងខេត្តគោលដៅចំនួន៧ គឺខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ និងព្រៃវែងដែលមានក្រុង ស្រុកចំនួន៣៧ និងឃុំ សង្កាត់ចំនួន២៧០។ ថវិកាសរុបរបស់គម្រោងមានចំនួន៦៦លានដុល្លារ ក្នុងនោះថវិការបស់ ADB មានចំនួន៥០លានដុល្លារ ថវិការបស់ IFAD មានចំនួន១០លានដុល្លារ និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលមានចំនួន៦លានដុល្លារ។

ក្នុងឆ្នាំ២០២១ គម្រោងគ្រោងថវិកាសរុបចំនួន៧៨.៨៤៨ លានរៀល និងបានចំណាយសរុប ចំនួន២៥.៦៥៣លានរៀល។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមានដូចខាងក្រោម ៖

- គម្រោងហេដ្ឋារចនាសម្ព័ន្ធសរុបចំនួន២៤៤គម្រោង ត្រូវបានជ្រើសរើស ក្នុងនោះគម្រោងផ្លូវលំចំនួន២០០ និងគម្រោងជារាសាស្រ្តចំនួន៤៤។ ការសាងសង់គម្រោងចំនួន២២ ក្នុងចំណោមគម្រោងសរុបចំនួន២៤៤ ត្រូវបានបញ្ចប់
- ឃុំគោលដៅទាំង២៧០បានបង្កើតមូលនិធិអភិវឌ្ឍឃុំ ទទួលបានការផ្ទេរមូលនិធិ និងបានជ្រើសរើសអ្នកផ្តល់ព័ត៌មានចល័តឃុំ។
- ក្រុមប្រឹក្សាឃុំក្នុងខេត្តគោលដៅទាំងអស់ទទួលការបណ្តុះបណ្តាលអំពីសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងដែលបានធ្វើបច្ចុប្បន្នភាព
- ក្រុមកែលម្អជីវភាពចំនួន៧០២បានបង្កើត និងដំណើរការក្នុងឃុំគោលដៅថ្មីទាំងអស់ដែលមានសមាជិកសរុបចំនួន១៧.៥៤៣នាក់ ក្នុងនោះមានស្ត្រីចំនួន៧៤% និង



Vda

សមាជិកគណៈកម្មការមានចំនួន២.១០៦នាក់ ស្ត្រីចំនួន៥៦%។

✓ គម្រោងបែងចែកដី ដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហានទី២ (LASED II) ៖

គម្រោងនេះមានរយៈពេល៥ឆ្នាំ ចាប់ផ្តើមពីខែសីហាឆ្នាំ២០១៦ ដល់ខែធ្នូឆ្នាំ២០២១ និងអនុវត្តក្នុងខេត្តគោលដៅចំនួន៥ គឺខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ ត្បូងឃ្មុំ និងខេត្តក្រចេះដែលមានស្រុក គោលដៅចំនួន៧ និងឃុំគោលដៅចំនួន១២។ ថវិកាសរុបរបស់គម្រោងមានចំនួន២៦,៨៦លាន ដុល្លារ ក្នុងនោះថវិការបស់ IDA-WB មានចំនួន២៥,០៦លានដុល្លារ និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលមានចំនួន១,៨០លានដុល្លារ។

ក្នុងឆ្នាំ២០២១ គម្រោងមានថវិកាសរុបចំនួន១៤.៨៩៥លានរៀល និងបានចំណាយថវិកាចំនួន៩.៧៣០លានរៀល។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមានដូចជា ៖

- គម្រោងផ្លូវក្រាលគ្រួសក្រហម២គម្រោង
- លូប្រឡាយចំនួន២គម្រោង
- មណ្ឌលសុខភាពនៅ សហគមន៍១គម្រោង
- សាងសង់អាងស្តុកទឹកសម្រាប់សហគមន៍នៅខេត្តក្រចេះ កំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង
- ផ្ទាំងប៉ាណូ៥គម្រោងនៅខេត្តគោលដៅទាំងប្រាំ
- សង់សាលារៀន៨ខ្នងនៅខេត្តត្បូងឃ្មុំ កំពង់ធំ កំពង់ឆ្នាំង និងកំពង់ស្ពឺ។

✓ គម្រោងលើកកម្ពស់សេវាសង្គម ឬកម្មវិធីសិទ្ធិកុមាររបស់អង្គការ UNICEF ៖

កម្មវិធីនេះមានរយៈពេល៥ឆ្នាំពីឆ្នាំ២០១៩-២០២៣ ដែលអនុវត្តនៅក្នុងរាជធានី ខេត្តគោលដៅចំនួន៧ គឺរាជធានីភ្នំពេញ ខេត្តបាត់ដំបង សៀមរាប ក្រចេះ រតនគិរី កណ្តាល និងខេត្តព្រះសីហនុ និងមានថវិកាសរុបចំនួនជាង១២១,៦លានដុល្លារ។

ក្នុងឆ្នាំ២០២១ គម្រោងបានគ្រោងថវិកាសរុបចំនួន១.១៦៨លានរៀល និងបានចំណាយថវិកាអស់ជាង១.១៥៩លានរៀល។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមានដូចជា ៖

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយសេចក្តីណែនាំបន្ថែមលេខ១៤៩ស្តីពីការរៀបចំកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សៀវភៅណែនាំស្តីពីពានរង្វាន់សេវាសង្គមសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងអនុម័តនៅថ្ងៃទី២៥ មីនា ឆ្នាំ២០២១ និងដាក់ឱ្យអនុវត្តសាកល្បងនៅក្នុងខេត្តគោលដៅយូនីសេហ្វទាំង៧គឺខេត្តបាត់ដំបង សៀមរាប ក្រចេះ រតនគិរី ព្រះសីហនុ កណ្តាល និងរាជធានីភ្នំពេញ ព្រមទាំងបានរៀបចំវគ្គគ្រូឧទ្ទេសអំពីសៀវភៅណែនាំនេះដល់ខេត្តគោលដៅទាំង៧ និងមន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានរដ្ឋបាល
- បានរៀបចំ និងអនុម័តឯកសារស្តីពីការអនុវត្តសេវាសង្គមនៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌក្នុងខែមិថុនា ២០២១ និងបានរៀបចំវគ្គបណ្តុះបណ្តាលអំពីឯកសារនេះ និងការរៀបចំផែនទីសេវាសង្គមដល់រដ្ឋបាលថ្នាក់ក្រោមជាតិជាតំបន់គោលដៅ

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ក.ន.ក. និង អំពីការជ្រើសរើសមន្ត្រីក្រៅក្របខ័ណ្ឌរបស់ឃុំ សង្កាត់ និងកិច្ចការពារកុមារ
- បានរៀបចំវគ្គបណ្តុះបណ្តាលដល់ថ្នាក់ក្រោមជាតិអំពីការបញ្ចូលទិន្នន័យគម្រោងអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសិក្ខាតាមសរុបចំនួន១៧៨នាក់
- បានបង្កើតកម្មវិធីអំពីប្រព័ន្ធព័ត៌មានគម្រោងនៅក្នុងទូរសព្ទដៃ
- បានរៀបចំសិក្ខាសាលាស្តីពីការបញ្ចូលគម្រោងសេវាសង្គមក្នុងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងផែនការប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានសិក្ខាកាមចូលរួម ចំនួន១៧៣នាក់
- វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញរយៈពេល១ថ្ងៃ ស្តីពីជំនាញបង្វឹកដល់គ្រូបង្វឹកថ្នាក់រាជធានី ខេត្តដែលមានអ្នកចូលរួមចំនួន៥១នាក់
- វគ្គបណ្តុះបណ្តាលគ្រូបង្គោល២៥រាជធានី ខេត្ត រយៈពេល៤ថ្ងៃស្តីពីការអនុវត្តការងារ សេវាសង្គមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ដែលមានអ្នកចូលរួមសរុប ចំនួន ១១៨នាក់។

✓ <u>កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE) ៖</u>

កម្មវិធីនេះមានរយៈពេល៧ ឆ្នាំ ចាប់ផ្តើមពីខែតុលា ឆ្នាំ២០១៥ ដល់ខែមីនា ឆ្នាំ២០២២ និង អនុវត្តក្នុងខេត្តគោលដៅចំនួន ៨ ខេត្ត គឺខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ព្រះវិហារ ក្រចេះ ព្រៃវែង ស្វាយរៀង និងខេត្តកំពត ដែលមានស្រុកចំនួន៣២ និងឃុំចំនួន១១០។ ថវិកាសរុបរបស់គម្រោងមាន ចំនួនជាង២១,២លានដុល្លារ ក្នុងនោះថវិការបស់ IFAD មានចំនួន១៤លានដុល្លារ និងថវិកាបដិភាគ របស់រាជរដ្ឋាភិបាលមានចំនួន៧,២លានដុល្លារ។

ក្នុងឆ្នាំ២០២១ គម្រោងបានគ្រោងថវិកាចំនួន១១.២០០លានរៀល និងបានចំណាយអស់ចំនួន ៦.៥៧៩លានរៀល។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមានដូចជា ៖

- គម្រោងហេដ្ឋរចនាសម្ព័ន្ធដែលធន់នឹងការប្រែប្រួលអាកាសធាតុចំនួន៣១គម្រោងក្នុងឃុំចំនួន៣១ ស្រុកចំនួន២៤ និងខេត្តគោលដៅចំនួន៨បានជ្រើសរើស និងគាំទ្រដោយ មូលនិធិវិនិយោគធន់នឹងការប្រែប្រួលអាកាសធាតុដែលមានថវិកាសរុបចំនួន១,២លាន ដុល្លារ និងគ្រួសារចំនួន២០.៣៩៣គ្រួសារនឹងទទួលបានទឹកប្រើប្រាស់ពីគម្រោងសម្រាប់ កសិកម្មរបស់ខ្លួន
- ឃុំចំនួន៤៨បានរៀបចំកិច្ចប្រជុំអំពី VRA បានរៀបចំផែនទីឃុំស្តីពី ភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ និងបានបញ្ជ្រាប់ភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងផែនការអភិវឌ្ឍ៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ឃុំ
- ស្រុកគោលដៅចំនួន២៤បានរៀបចំសិក្ខាសាលាស្តីពីភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីពិនិត្យ និងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុ



Vdg 𝒩

របស់ស្រុក ព្រមទាំងការរៀបចំផែនទីភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុតាមប្រព័ន្ធ GIS។

- ជាមួយគ្នានេះដែរស្រុកគោលដៅទាំង២៤ ក៏បានរៀបចំសិក្ខាសាលាជ្រើសរើសគម្រោងនៅពេលមុន និងនៅចុងបញ្ចប់ ដើម្បីជ្រើសរើសគម្រោងទទួលមូលនិធិវិនិយោគធន់នឹងការប្រែប្រួលអាកាសធាតុ។

✓ <u>**គម្រោងផ្គត់ផ្គង់ទឹកស្អាតធន់នឹងការប្រែប្រួលអាកាសធាតុ (LGCC-RESIWAS) ៖**</u>

គម្រោងនេះមានរយៈពេល២ឆ្នាំ ចាប់ផ្តើមអនុវត្តពីឆ្នាំ២០២០ដល់ឆ្នាំ២០២១ និងអនុវត្តក្នុងខេត្តបាត់ដំបងដែលមានស្រុកគោលដៅចំនួន១ និងឃុំគោលដៅចំនួន១។ ថវិកាសរុបរបស់គម្រោងមានចំនួន ៦១៨.៤៨៨ដុល្លារដែលគាំទ្រដោយអង្គការ UNCDF។

ក្នុងឆ្នាំ២០២១ គម្រោងបានគ្រោងថវិកាចំនួន២.១៤១លានរៀល និងបានចំណាយអស់ចំនួន ២៧៦លានរៀល។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមានដូចជា ៖

- អង្គការ GRET ត្រូវបានជ្រើសរើសសម្រាប់រៀបចំប្លង់បច្ចេកទេសនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅឃុំបាសាក់
- ការអង្កេតអំពីភូគព្ភសាស្ត្រនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅក្នុងឃុំបាសាក់ ត្រូវបានបញ្ចប់ និងបានរៀបចំរបាយការណ៍ស្តីពីប្លង់នៃប្រព័ន្ធជូនលេខាធិការដ្ឋាន គ.ជ.អ.ប.
- បានរៀបចំ និងដាក់ឱ្យអនុវត្តនូវសៀវភៅណែនាំរបស់ គ.ជ.អ.ប. ស្តីពីការគ្រប់គ្រងគម្រោង
- សេចក្តីណែនាំសម្រាប់សាកល្បងការបញ្ជ្រាបគោលនយោបាយសុវត្ថិភាពបរិស្ថាន និងសង្គម និងគោលនយោបាយសមភាពយេនឌ័រក្នុងការអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ខេត្តចំនួន៤៥នាក់
- ឯកសារទស្សនទានស្តីពីគម្រោង LGCC3 ដែលបានកែសម្រួលចុងក្រោយត្រូវបានរៀបចំ និងដាក់ជូន GCF។

✓ <u>**កម្មវិធីកំណែទម្រង់រដ្ឋបាលតាមបែបវិមជ្ឈការ (GIZ-DAR) ៖**</u>

កម្មវិធីនេះមានរយៈពេល៤ ឆ្នាំ ចាប់ផ្តើមពីខែមិថុនា ឆ្នាំ២០១៩ ដល់ខែមេសាឆ្នាំ២០២២ អនុវត្តនៅក្នុងខេត្តបាត់ដំបង និងមានថវិកាសរុបចំនួន៥៧,០៥លានដុល្លារ។

ក្នុងឆ្នាំ២០២១ កម្មវិធីនេះគ្រោងថវិកាចំនួន៦.៥៨៣លានរៀល។ លទ្ធផលសំខាន់ៗដែលកម្មវិធីសម្រេចបានត្រូវបានធ្វើសមាហរណកម្មក្នុងផ្នែកទី២នៃរបាយការណ៍។ ខាងក្រោមជាសេចក្តីសង្ខេបនៃលទ្ធផលទាំងនោះ ៖

- បានគាំទ្រនាយកដ្ឋានមុខងារ និងធនធាននៃក្រសួងមហាផ្ទៃក្នុងការពិនិត្យ កែសម្រួល និងការរៀបចំវគ្គបណ្តុះបណ្តាលអំពីការិយាល័យផ្តល់សេវាច្រកចេញចូលតែមួយ និងការិ



Vdes

យាល័យប្រជាពលរដ្ឋនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានគាំទ្រសាលាជាតិរដ្ឋបាលមូលដ្ឋានក្នុងការរៀបចំឯកសារបណ្តុះបណ្តាល និងសេចក្តីណែនាំនានា ព្រមទាំងរៀបចំវគ្គបណ្តុះបណ្តាលអំពីមុខងារនានា ដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដូចជា មុខងារក្នុងវិស័យសុខាភិបាល និងវិស័យអប់រំជាដើម
- បានគាំទ្រក្រសួងមុខងារសាធារណៈក្នុងការរៀបចំលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាស្តីពីការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការផ្តល់សេវាសាធារណៈ និងការរៀបចំចងក្រងជាឯកសារ និងព័ត៌មាននានាអំពីមេរៀន បទពិសោធន៍ល្អៗពាក់ព័ន្ធ
- បានអនុវត្តការអង្កេតអំពីភាពពេញចិត្ត ក្នុងចំណោមសមាជិកនានានៃបណ្តាញអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារនៅក្នុងខេត្តបាត់ដំបងអំពីភាពជាដៃគូក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដើម្បីឆ្លុះបញ្ចាំងអំពីយន្តការនៃការចូលរួមរបស់ប្រជាពលរដ្ឋដែលមានបច្ចុប្បន្ននៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

✓ <u>គម្រោងពង្រឹងប្រព័ន្ធស្បៀងមូលដ្ឋានដែលធន់នឹងការប្រែប្រួលអាកាសធាតុ (SRELFOODS) ៖</u>

កម្មវិធីនេះមានរយៈពេល១ ឆ្នាំ គឺឆ្នាំ២០២១ អនុវត្តនៅក្នុងខេត្តគោលដៅចំនួន៣ គឺខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តកំពង់ឆ្នាំង ដែលរួមមាន៣ស្រុក និង៣ឃុំ និងមានថវិកាសរុបចំនួន២៣៥.៨០៥ ដុល្លារ គាំទ្រដោយអង្គការស្បៀងអាហារពិភពលោក WFP។

ក្នុងឆ្នាំ២០២១ កម្មវិធីនេះគ្រោងថវិកាចំនួន៩៤៣លានរៀល និងបានចំណាយអស់ចំនួន១៤៩ លានរៀល។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមានដូចខាងក្រោម ៖

- វគ្គបណ្តុះបណ្តាលអំពីចំណេះដឹងនៃការបញ្ជ្រាបភាពបន្សាំទៅការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយក្នុងកម្មវិធីនិយោគឃុំ បានរៀបចំសម្រាប់ក្រុមការងារខេត្ត និងស្រុកគោលដៅចំនួន៤៩នាក់ក្នុងនោះមានស្ត្រីចំនួន៨នាក់
- សមាជិកក្រុមប្រឹក្សាឃុំ និងសមាជិកគណៈកម្មាធិការកសាងផែនការឃុំចំនួនជាង១៣៦ នាក់ក្នុងនោះមានស្ត្រីចំនួន៣២នាក់ ទទួលបានការបណ្តុះបណ្តាលអំពីទស្សនទានស្តីពីការប្រែប្រួល អាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ
- គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចចំនួន២១ក្នុងឃុំគោលដៅចំនួន១៦ បានរៀបចំ និងអនុម័តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. សម្រាប់អនុវត្តក្នុងឆ្នាំ២០២២
- កុងស៊ុលតង់បច្ចេកទេសចំនួន៥នាក់ ត្រូវបានជ្រើសរើសសម្រាប់សិក្សា និងរៀបចំប្លង់គម្រោងខាងលើ។

✓ <u>គម្រោងលើកកម្ពស់អាហារូបត្ថម្ភ (CNP) ៖</u>

កម្មវិធីនេះមានរយៈពេល៦ ឆ្នាំដែលចាប់ផ្តើមពីឆ្នាំ២០១៩ដល់ឆ្នាំ២០២៤ អនុវត្តនៅក្នុងខេត្តគោលដៅចំនួន៧ គឺខេត្តព្រះវិហារ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ក្រចេះ កំពង់ឆ្នាំង និងកោះកុង និង មានថវិកាសរុបចំនួន១០,៨លានដុល្លារដែលគាំទ្រដោយធនាគារពិភពលោក WB ។

ក្នុងឆ្នាំ២០២១ កម្មវិធីនេះគ្រោងថវិកាចំនួន១០.០៦៣លានរៀល និងបានចំណាយអស់៨០៣លានរៀល។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមានដូចខាងក្រោម ៖

- បានរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីបង្គោលថ្នាក់ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ចំនួន ៤៨១នាក់អំពីសៀវភៅណែនាំស្តីពីការមូលនិធិផ្តល់សេវា និងការវាយតម្លៃមូលនិធិផ្តល់សេវាឃុំ សង្កាត់
- អ្នកវាយតម្លៃថ្នាក់ខេត្តចំនួន១៩នាក់បានបណ្តុះបណ្តាល និងផ្តល់វិញ្ញាបណ្ណបត្របញ្ជាក់
- គណនីករ និងបេឡាករក្រុង ស្រុក និងឃុំ សង្កាត់ចំនួន១៩៨នាក់ទទួលបានការបណ្តុះបណ្តាលអំពីការគ្រប់គ្រងហិរញ្ញវត្ថុ
- ក្រុង ស្រុកចំនួន១៤ និងឃុំ សង្កាត់ចំនួន៧៣បានវាយតម្លៃអំពីភាពរួចជាស្រេច ក្នុង នោះមានក្រុង ស្រុកចំនួន២ និងឃុំ សង្កាត់ចំនួន៨ទទួលបានមូលនិធិពីលេខាធិការដ្ឋាន គ.ជ.អ.ប.
- ក្រុមស្ម័គ្រចិត្តផ្នែកសុខភាពចំនួន៧៤៩ក្រុមបានជ្រើសរើស និងចុះកិច្ចសន្យា
- កញ្ចប់លទ្ធកម្មចំនួន៩នៃទំនិញនិងសេវាទីប្រឹក្សាត្រូវបានអនុវត្តបញ្ចប់។

✓ <u>**កម្មវិធីកំណែទម្រង់រដ្ឋបាលតាមបែបវិមជ្ឈការ (Empower) ៖**</u>

កម្មវិធីនេះមានរយៈពេល២ ឆ្នាំ ចាប់ផ្តើមពីឆ្នាំ២០២០ដល់ឆ្នាំ២០២២ អនុវត្ត នៅក្នុងខេត្តតាកែវ និងខេត្តពោធិ៍សាត់ និងមានថវិកាសរុបចំនួន១៧១.១៩២ដុល្លារ ដែលគាំទ្រដោយកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ UNEP។

ក្នុងឆ្នាំ២០២១ កម្មវិធីនេះគ្រោងថវិកាចំនួន៥៥០លានរៀល និងបានចំណាយអស់ចំនួន២៧២លានរៀល។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមានដូចខាងក្រោម ៖

- បានចុះអនុស្សារណៈយោគយល់រវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយធនាគារកសិកម្ម និងអភិវឌ្ឍជនបទស្តីពីកិច្ចសហប្រតិបត្តិការរបស់ធនាគារជាមួយគម្រោង Empower ក្នុងការគាំទ្រស្ត្រីក្រុមគោលដៅក្នុងការងារភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ
- បានចុះអនុស្សារណៈយោគយល់រវាងគម្រោង Empower ជាមួយអង្គការ SOGE និង អង្គការ Ecosum ក្នុងការផ្គត់ផ្គង់ និងចែកចាយសម្ភារៈ និងឧបករណ៍ថាមពលកកើត ឡើងវិញទៅឱ្យក្រុមគោលដៅនៃគម្រោង
- បានបង្កើតមូលនិធិគម្រោង Empower ដើម្បីគាំទ្រដល់ក្រុមស្ត្រី និងស្ត្រីវិនិយោគិនដែលជាក្រុមគោលដៅ ដែលពាក់ព័ន្ធនឹងការលើកកម្ពស់ភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងថាមពលនៃការកកើតឡើងវិញ និងបានផ្សព្វផ្សាយដល់ក្រុមគោលដៅ និងអ្នកពាក់ព័ន្ធនានា
- បានចុះកិច្ចព្រមព្រៀងរវាងគម្រោង Empower ជាមួយអង្គការ S-RET, ASPIRE និង AIMS ដើម្បីកៀរគរធនធាន ការវិនិយោគ និងការអភិវឌ្ឍសមត្ថភាពដល់ក្រុមគោលដៅ



Vda

– សហការជាមួយអង្គការ SHE investment រៀបចំវគ្គបណ្តុះបណ្តាលដល់សហគ្រិនជាស្ត្រីស្តីពីការអភិវឌ្ឍអាជីវកម្មដែលមានសិក្ខាកាមសហគ្រិនជាស្ត្រីចំនួន០៦រូប និងបុរសចំនួន០១រូប និងវគ្គបណ្តុះបណ្តាលដល់ក្រុមស្ត្រីស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងអាជីវកម្មផ្ទាល់ខ្លួនសិក្ខាកាមជាស្ត្រីចំនួន១០៧ រូប

– បានដំឡើងសូឡាបូមទឹក១គ្រឿងសម្រាប់បន្លែ សូឡាភ្ញាស់ស៊ុតមាន់ សូឡាផលិតទឹកសុទ្ធសរុប០៣គ្រឿង។

✓ <u>គម្រោងបង្កើតបរិយាកាសអំណោយផលប្រកបដោយចីរភាព(BESD)៖</u>

កម្មវិធីនេះមានរយៈពេល៣ឆ្នាំ ចាប់ផ្តើមពីឆ្នាំ២០១៩ដល់ឆ្នាំ២០២១ អនុវត្តនៅក្នុងខេត្តកែប និងមានថវិកាសរុបចំនួន៥៥.៦៣៤ដុល្លារ។

ក្នុងឆ្នាំ២០២១ កម្មវិធីនេះគ្រោងថវិកាចំនួន៣៤០លានរៀល និងបានចំណាយអស់ចំនួន៣៤០លានរៀល។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមានដូចខាងក្រោម ៖

– សកម្មភាពនៃការគ្រប់គ្រងសំណល់រឹងទីប្រជុំជនត្រូវបានបញ្ចូលក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុងពីឆ្នាំ២០២១-២០២៣

– ដេប៉ូចល័តសម្រាប់ចាក់កាកសំណល់រឹងចំនួន៣ត្រូវបានសាងសង់ក្នុងទីក្រុងកែប

– មន្ត្រី និងប្រជាពលរដ្ឋក្រុងកែបមានចំណេះដឹង និងសមត្ថភាពកើនឡើងអំពីការប្រមូល និងការគ្រប់គ្រងកាកសំណល់រឹងទីប្រជុំជន។

✓ <u>គម្រោងប្រើប្រាស់បច្ចេកវិទ្យាថាមពលពន្លឺព្រះអាទិត្យសម្រាប់វិស័យកសិកម្ម (STARD)៖</u>

គម្រោងនេះមានរយៈពេល១ឆ្នាំ ចាប់ផ្តើមអនុវត្តពីខែមិថុនាដល់ខែធ្នូឆ្នាំ២០២១ នៅក្នុងខេត្តសៀមរាប និងខេត្តកំពង់ធំរួមមាន ស្រុកចំនួន៧ ឃុំចំនួន៣៦ និងភូមិចំនួន៥៦។ គោលបំណងរបស់គម្រោង គឺលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាថាមពលពន្លឺព្រះអាទិត្យសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ និងមានថវិកាសរុបចំនួន៦៥.៦៧៦ដុល្លារ ស្មើនឹង២៦២លានរៀល។

ក្នុងឆ្នាំ២០២១ គម្រោងនេះបានចំណាយអស់ចំនួន២៣៤លានរៀល។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមានដូចខាងក្រោម ៖

– បានរៀបចំសិក្ខាសាលាចាប់ផ្តើម និងផ្សព្វផ្សាយអំពីគម្រោងដល់ភាគីពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

– បានសម្របសម្រួល និងគាំទ្រជំនាញការ UNDP ក្នុងការសិក្សាលទ្ធភាពអំពីប្រព័ន្ធបូមទឹក និងការវាយតម្លៃទីផ្សារសម្រាប់ការអភិវឌ្ឍខ្សែច្រវ៉ាក់តម្លៃកសិកម្ម សម្រាប់កសិករខ្នាតតូចក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាប

– បានសម្របសម្រួល និងគាំទ្រជំនាញការ UNDP ក្នុងការចុះប្រមូលព័ត៌មានស្តីពីទីតាំងសម្រាប់បូមទឹកដោយប្រើប្រព័ន្ធសូឡា និងពិភាក្សាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិអំពីដីសាធារណៈសម្រាប់សាងសង់ផ្សារកសិករ

- បានរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្តីពីការវាយតម្លៃ ទីតាំង ការរៀបចំប្លង់ ការតម្លើង ប្រតិបត្តិការ និងការថែរក្សាប្រព័ន្ធបូមទឹកប្រើសូឡា
- បានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងអំពីគម្រោងដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

✓ <u>ការលើកកម្ពស់ការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការដោយ CSOs ( CSOs-ISAF ) ៖</u>

ក្នុងឆ្នាំ២០២១ អង្គការសង្គមស៊ីវិលដែលចូលរួមអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ រួមមានដូចជា អង្គការ WVI, OXFAM, CARE និង FHI៣៦០ តាមរយៈការចុះអនុស្សារណយោគ យល់រវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយអង្គការទាំងនេះ និងមានថវិកាសរុបចំនួនជាង ៥.៣០០ លានដុល្លារ និងអនុវត្តនៅក្នុងខេត្តគោលដៅចំនួន២២ ដែលរួមមានក្រុង ស្រុក ខណ្ឌ ចំនួន៩៨ រដ្ឋបាល ឃុំ សង្កាត់ចំនួន៧១៥ សាលាបឋមសិក្សាចំនួន ២.៩៦១ និងមណ្ឌលសុខភាពចំនួន៥៣២។

ក្នុងឆ្នាំ២០២១ អង្គការទាំងអស់បានគ្រោងថវិកាសរុបចំនួន១៥.២៥២លានរៀល និងបានចំណាយអស់ចំនួន១០.១៦៩លានរៀល។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមានដូចខាងក្រោម ៖

- បានរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីគណនេយ្យភាពសហគមន៍ CAF ចំនួន៤៧វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន៣.៤៥៤នាក់ក្នុងនោះមានស្ត្រីចំនួន២.១៤៣នាក់
- បានរៀបចំការផ្សព្វផ្សាយព័ត៌មានសម្រាប់ប្រជាពលរដ្ឋ I4C ចំនួន២.២៦៨លើកដែលមានអ្នកចូលរួមសរុបចំនួន៣៥០.៤៨៧នាក់ក្នុងនោះស្ត្រីមានចំនួន១៩៤.៩៥៥នាក់
- បានរៀបចំកិច្ចប្រជុំដាក់ពិន្ទុសហគមន៍ចំនួន២.១៥២លើក ដែលមានអ្នកចូលរួមសរុបចំនួន ៤០.១១២នាក់ក្នុងនោះមានស្ត្រីចំនួន៣០.០១២នាក់។
- បានរៀបចំកិច្ចប្រជុំរួម និងបង្កើត JAAP ចំនួន៦៦៣លើក ដែលមានអ្នកចូលរួមសរុបចំនួន ៩.៩៧៥នាក់ក្នុងនោះមានស្ត្រីចំនួន៦.១៣៥នាក់ ។

វឌ្ឍនភាពលម្អិតនៃការអនុវត្តសកម្មភាពជាអាទិភាព និងសូចនាករសំខាន់ៗមានបរិយាយនៅក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២។

## ៣. ស្ថានភាពហិរញ្ញវត្ថុ

របាយការណ៍នៃការអនុវត្តថវិកា ផ.ស.ថ. ឆ្នាំ២០២១ របស់ គ.ជ.អ.ប. ផ្តោតជាសំខាន់លើការ អនុវត្តថវិការបស់សេចក្តីសម្រេចរួមឆ្នាំ២០២១ ដែលបានចុះហត្ថលេខារវាង គ.ជ.អ.ប. ជាមួយក្រសួង ស្ថាប័ន និងរវាង គ.ជ.អ.ប. ជាមួយរដ្ឋបាលរាជធានី ខេត្ត និងការអនុវត្តថវិការបស់គម្រោង កម្មវិធីដាច់ ដោយឡែកមួយចំនួន ជាពិសេសគម្រោង កម្មវិធីដែលស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់លេខាធិ ការដ្ឋាន គ.ជ.អ.ប.។

ក្នុងឆ្នាំ២០២១ ថវិកាសរុបនៃសេចក្តីសម្រេចរួមរវាង គ.ជ.អ.ប. និងក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តមានចំនួន **២៦.០៤១** លានរៀល ស្មើនឹង**៦,៥៥** លានដុល្លារអាមេរិកដែលក្នុងនោះថវិការបស់លេខាធិការដ្ឋាន គ.ជ.អ.ប. មានចំនួន **៩.៥០០** លានរៀល ស្មើនឹង **២,៣៨** លានដុល្លារ ថវិកា របស់ក្រសួង ស្ថាប័នចំនួន **៥.៤៧៨** លានរៀល ស្មើនឹង **១,៣៧** លានដុល្លារ និងថវិការបស់រដ្ឋបាល រាជធានី

ខេត្ត និងក្រុង ស្រុក ខណ្ឌមានចំនួន ១១.០៦៣ លានរៀល ស្មើនឹង ២,៧៧ លានដុល្លារ។

ក្នុងឆ្នាំ២០២១ ចំណាយសរុបនៃការអនុវត្តថវិការបស់សេចក្ដីសម្រេចរួមឆ្នាំ២០២១ មានចំនួន ១៤.៨៨០ លានរៀល ស្មើនឹង ៣,៧២ លានដុល្លារ ក្នុងនោះចំណាយរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. មានចំនួន ៨.៩៤៥ លានរៀល ចំណាយរបស់ក្រសួង ស្ថាប័នមានចំនួន ៤២៩ លានរៀល និង ចំណាយរបស់ថ្នាក់ក្រោមជាតិមានចំនួនជាង ៥.៥០៧ លានរៀល។ ចំណាយទាំងនេះរួមបញ្ចូលទាំង ចំណាយនានានៃកិច្ចប្រតិបត្តិការជាប្រចាំដូចជា កិច្ចការរដ្ឋបាលទូទៅ ចំណាយបេសកកម្ម ចំណាយ លើប្រេងឥន្ធនៈនិងការដឹកជញ្ជូនដែលពាក់ព័ន្ធនឹងការអនុវត្តសកម្ម និងចំណាយពាក់ព័ន្ធផ្សេងទៀត។

**តារាងទី២ ៖ សង្ខេបថវិកាសេចក្ដីសម្រេចរួមឆ្នាំ២០២១ និងការចំណាយ (គិតជាលានរៀល)**

| ល.រ. | ស្ថាប័នអនុវត្ត | ថវិកា | ចំណាយ | សមតុល្យ |
|---|---|---|---|---|
| ១ | លេខាធិការដ្ឋាន គ.ជ.អ.ប. | 9,500 | 8,945 | **555** |
| ២ | ក្រសួង ស្ថាប័ននានា | 5,478 | 429 | **5,050** |
| ៣ | រដ្ឋបាលថ្នាក់ក្រោមជាតិ | 11,063 | 5,507 | **5,556** |
| | សរុប | **26,041** | **14,880** | **11,161** |

ចំពោះគម្រោងដាច់ដោយឡែក ថវិកាសរុបដែលគាំទ្រ ផ.ស.ថ. ឆ្នាំ២០២១ របស់ គ.ជ.អ.ប. មានចំនួន១៤៥.២៥១លានរៀល ស្មើនឹង៣៦,៣១លានដុល្លារ។ ក្នុងឆ្នាំ២០២១ ថវិកាចំណាយសម្រាប់ គាំទ្រសកម្មភាពនានាដែលបានអនុវត្តមានចំនួន៥៦.៦៥៥លានរៀល ស្មើនឹង១៤,១៦លានដុល្លារ។

**តារាងទី៣ ៖ សង្ខេបថវិកាគម្រោង កម្មវិធីនានា និងការចំណាយ (គិតជាលានរៀល)**

| ល.រ. | ស្ថាប័នអនុវត្ត | ថវិកា | ចំណាយ | សមតុល្យ |
|---|---|---|---|---|
| ១ | គម្រោង កម្មវិធីដាច់ដោយឡែកនានា | 145,251 | 56,655 | 88,597 |
| | សរុប | **145,251** | **56,655** | **88,597** |

គួរកត់សម្គាល់ថា មានក្រសួង ស្ថាប័ន និងគម្រោង កម្មវិធីដាច់ដោយឡែកមួយចំនួនពុំបានផ្ញើរបាយការណ៍ប្រចាំឆ្នាំ២០២១មកលេខាធិការដ្ឋាន គ.ជ.អ.ប. ឡើយ។ ដូច្នេះ ចំណាយសរុបជាក់ស្តែងក្នុងឆ្នាំ២០២១ អាចមានចំនួនច្រើនជាងតួលេខចំណាយសរុបដូចមានសង្ខេបក្នុងតារាងខាងលើ។

## ៤. បញ្ហាប្រឈម និងសំណើដំណោះស្រាយ

### ក. បញ្ហាប្រឈមជាគន្លឹះ

ក្នុងអំឡុងឆ្នាំ២០២១ បញ្ហាប្រឈមដ៏ធ្ងន់ធ្ងរដែលបានជួបប្រទះក្នុងការអនុវត្ត ផ.ស.ថ ឆ្នាំ២០២១ របស់ គ.ជ.អ.ប. គឺការរីករាលដាលនៃជម្ងឺឆ្លងកូវីដ-១៩ ដែលនាំឱ្យការអនុវត្តនៃអនុសកម្មភាពជាច្រើនត្រូវបានពន្យារពេល ឬផ្អាកដំណើរការ ព្រមទាំងមានការកាត់បន្ថយថវិកានៃ ផ.ស.ថ. ឆ្នាំ២០២១ របស់ស្ថាប័នអនុវត្តនានា ដើម្បីយកមកគាំទ្រដល់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺ នេះ។



Vda

អនុសកម្មភាពសំខាន់ៗដែលបានពន្យារពេលអនុវត្តរួមមាន ៖

- ការរៀបចំតាក់តែងកម្មវិធីជាតិដំណាក់កាលទី២
- ការរៀបចំឯកសារផែនការអនុវត្ត៥ឆ្នាំ (២០២១-២០២៥) ដំណាក់កាលទី១នៃកម្មវិធីជាតិដំណាក់កាលទី២
- ការរៀបចំឯកសារបច្ចេកទេសរបស់វិស័យនានាស្តីពីការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- កម្មវិធីអភិវឌ្ឍន៍សមត្ថភាព និងការបង្កើនចំណេះដឹងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិដូចជា វគ្គបណ្តុះបណ្តាលសម្រាប់ស្ត្រីជាថ្នាក់ដឹកនាំ លិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការអនុវត្តមុខងារ សៀវភៅណែនាំស្តីពីការអនុវត្ត និងការគ្រប់គ្រងគម្រោង
- ការរៀបចំប្រព័ន្ធទិន្នន័យសម្រាប់ការគ្រប់គ្រង (MIS) រដ្ឋបាលរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការចាប់ផ្តើមអនុវត្តគម្រោង Readiness របស់លេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីបំពេញល័ក្ខខ័ណ្ឌរបស់ GCF រួមបញ្ចូលទាំងការបង្កើត និងដាក់ឱ្យដំណើរការ និងអនុវត្តនូវគណៈកម្មការ ក្រុមការងារ សៀវភៅណែនាំ សេចក្តីណែនាំនានារបស់ គ.ជ.អ.ប. និងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ព្រមទាំងការរៀបចំវគ្គបណ្តុះបណ្តាលអំពីឯកសារទាំងនេះ
- ការគាំទ្រ និងអភិវឌ្ឍសមត្ថភាពរាជធានី ខេត្ត និងក្រុង ស្រុកក្នុងការអនុវត្តមុខងារនានាដែលបានផ្ទេរទៅឱ្យ
- ការរៀបចំបញ្ចប់ និងការបណ្តុះបណ្តាលអំពីគោលការណ៍ បែបបទ និងនីតិវិធីសម្រាប់ ការគ្រប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- ការរៀបចំ និងការអភិវឌ្ឍសមត្ថភាពផ្អែកលើតម្រូវការរបស់រាជធានី ខេត្ត
- ការអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន
- ការរៀបចំ និងការអនុវត្តគម្រោង SNIF និង
- ការអនុវតសកម្មភាពរបស់គម្រោង និងកម្មវិធីនានា។

## ខ. សំណើដំណោះស្រាយ

ដើម្បីពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២ លេខាធិការដ្ឋាន គ.ជ.អ.ប. បានកំណត់នូវសំណូមពរ និងអនុសាសន៍សម្រាប់ការដោះស្រាយបញ្ហាប្រឈមខាងលើដូចខាងក្រោម ៖

- ផ្តល់អាទិភាព និងពន្លឿនការរៀបចំ និងការអនុម័តផែនការអនុវត្ត៥ឆ្នាំដំណាក់កាលទី១ ពីឆ្នាំ ២០២១-២០៣០ (ផអ៥ទី១) នៃកជទី២
- ពង្រឹងការតាមដាន ការសម្របសម្រួល និងការគាំទ្រក្រសួង ស្ថាប័នក្នុងការរៀបចំគោល យោបាយ និងឯកសារបច្ចេកទេសនានាសម្រាប់ការអនុវត្តមុខងារ ដែលបានផ្ទេរទៅឱ្យក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត
- លើកកម្ពស់ការអនុវត្តការងារគណនេយ្យភាពសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ



Vdu

- ពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- លើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងមធ្យោបាយផ្សេងៗ
- ពង្រឹងការយកចិត្តទុកដាក់ក្នុងការរៀបចំ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធ MIS សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពង្រឹងការតាមដាន និងការអនុវត្ត និងការគ្រប់គ្រងគម្រោង Readiness ដែលគាំទ្រដោយ GCF
- ពង្រឹងកិច្ចសហការ និងផ្តល់ការគាំទ្រដៃគូនានាក្នុងការរៀបចំសំណើគម្រោងស្តីពីការប្រែប្រួលអាកាសធាតុ ដើម្បីស្នើសុំគាំទ្រថវិកាពី GCF។

## ៥. សកម្មភាពជាអាទិភាពសម្រាប់ឆ្នាំ២០២២

| ល.រ. | សកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| ១. | ការផ្សព្វផ្សាយឯកសារ កជទី២ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ២. | ពិនិត្យ កែសម្រួល និងអនុម័ត ផអ៥ទី១នៃ កជទី២ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៣. | ពិនិត្យ និងអនុម័ត ផ.ស.ថ. ឆ្នាំ២០២២ ដោយ គ.ជ.អ.ប. | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៤. | រៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប. | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៥. | រៀបចំកិច្ចប្រជុំរបស់អនុគណៈកម្មការ គ.ជ.អ.ប. | អនុគណៈកម្មការ គ.ជ.អ.ប. |
| ៦. | រៀបចំកិច្ចប្រជុំសម្របសម្រួលរវាងកម្មវិធីកំណែទម្រង់៣បូក១ | លេខាធិការដ្ឋាន នៃកំណែទម្រង់៣បូក១ |
| ៧. | ពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធផ្អែកលើមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | ក្រសួងស្ថាប័នពាក់ព័ន្ធ |
| ៨. | រៀបចំបញ្ចប់ និងដាក់ឱ្យដំណើរការនូវគណៈកម្មការ និងក្រុមការងារនានារបស់ គ.ជ.អ.ប. និងលេខាធិការដ្ឋាន គ.ជ.អ.ប.<br>➢ ក្រុមការងារក្រមសីលធម៌ និងសវនកម្មផ្ទៃក្នុងរបស់ គ.ជ.អ.ប.<br>➢ គណៈកម្មការត្រួតពិនិត្យការអនុវត្តកម្មវិធីរបស់ គ.ជ.អ.ប.<br>➢ គណៈកម្មការ និងក្រុមការងារពាក់ព័ន្ធផ្សេងទៀត | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៩. | រៀបចំបញ្ចប់ និងអនុម័តនូវសៀវភៅណែនាំ និងសេចក្តីណែនាំនានារបស់ គ.ជ.អ.ប.<br>➢ យន្តការ និងនីតិវិធីសម្រុះសម្រួលដោះស្រាយបណ្តឹង<br>➢ សៀវភៅណែនាំពាក់ព័ន្ធផ្សេងទៀត | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ១០. | ការអភិវឌ្ឍសមត្ថភាពអំពីសៀវភៅណែនាំ និងសេចក្តីណែនាំស្តីពី កិច្ច | លេខាធិការដ្ឋាន គ.ជ.អ.ប. |

| ល.រ. | សកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | ប្រតិបត្តិការកម្មវិធី សវនកម្មផ្ទៃក្នុង។ល។ | |
| ១១. | សហការ និងគាំទ្រដៃគូនានាក្នុងការរៀបចំឯកសារទស្សនទាន និងសំណើគម្រោងនានា ដើម្បីដាក់ជូន GCF | លេខាធិការដ្ឋាន គ.ជ.អ.ប. និងដៃគូពាក់ព័ន្ធ |
| ១២. | លើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានអំពីកំណែទម្រង់ D&D | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ១៣. | អនុវត្តសវនកម្មផ្ទៃក្នុងលើគម្រោង កម្មវិធីនានា | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ១៤. | ពង្រឹងសមត្ថភាពសមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | អគ្គលេខាធិការដ្ឋាន ASAC |
| ១៥. | ពង្រឹងការតាមដាន និងគាំទ្ររាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារដែលបានផ្ទេរ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ១៦. | ពិនិត្យ និងបែងចែកច្បាស់លាស់នូវមុខជាជម្រើស និងមុខងារជាកាតព្វកិច្ចរបស់រដ្ឋបាលក្រុង ស្រុក | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ១៧. | ពង្រឹងការតាមដាន និងគាំទ្រឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តគម្រោង | ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ |
| ១៨. | សិក្សាពីជម្រើសនានាក្នុងការបង្កើតរដ្ឋបាលខេត្តឱ្យមានលក្ខណៈជា រដ្ឋបាលតំបន់ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ១៩. | សិក្សា និងរៀបចំកញ្ចប់ថវិកាដាក់លាក់សម្រាប់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ២០. | ពង្រឹងយន្តការនានាក្នុងការសម្រុះសម្រួលដោះស្រាយបណ្ដឹងរបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការផ្ដល់សេវាសាធារណៈ | ក្រសួងមហាផ្ទៃ |
| ២១. | ពង្រឹង និងគាំទ្រការអនុវត្តការងារគណនេយ្យភាពសង្គមក្នុងតំបន់គោលដៅនៃរដ្ឋបាលថ្នាក់លក្រោមជាតិ | លេខាធិការដ្ឋាន គ.ជ.អ.ប. រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍនានា |
| ២២. | កែសម្រួល និងដាក់ឱ្យអនុវត្តនូវគោលការណ៍ បែបបទ និងនីតិវិធីសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | ក្រសួងមុខងារសាធារណៈ |
| ២៣. | សិក្សាលទ្ធភាព និងរៀបចំការសាងសង់សាលា NASLA | ក្រសួងមហាផ្ទៃ |
| ២៤. | រៀបចំ និងអនុវត្តកម្មវិធីបណ្ដុះបណ្ដាលដោយ NASLA | ក្រសួងមហាផ្ទៃ |
| ២៥. | ពង្រឹង និងអនុវត្តសកម្មភាពអភិវឌ្ឍសមត្ថភាពក្រុង ស្រុក ខណ្ឌដោយរាជធានី ខេត្ត | រាជធានី ខេត្ត |
| ២៦. | ពង្រឹង និងអនុវត្តសកម្មភាពអភិវឌ្ឍសមត្ថភាពក្រុង ស្រុក ខណ្ឌដោយមន្ទីរជំនាញរាជធានី ខេត្ត | មន្ទីរជំនាញរាជធានី ខេត្ត |

| ល.រ. | សកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវ |
| --- | --- | --- |
| ២៧. | រៀបចំ និងអនុវត្តវគ្គបណ្តុះបណ្តាលអំពីសមភាពយេនឌ័រ សមធម៌ និងបរិយាប័ន្នសង្គម | លេខាធិការដ្ឋាន គ.ជ.អ.ប. រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ២៨. | ពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋរដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើកម្មវិធីវិនិយោគបីឆ្នាំរំកិល | ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ២៩. | រៀបចំវគ្គរំលឹកឡើងវិញអំពីប្រព័ន្ធកសាងផែនការថ្នាក់ក្រោមជាតិរួមបញ្ចូលទាំងឧបករណ៍ និងទិន្នន័យសម្រាប់កសាងផែនការ | ក្រសួងផែនការ រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៣០. | ពិនិត្យ និងកែសម្រួលប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៣១. | រៀបចំ និងផ្ទេរទ្រព្យសម្បត្តិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ |
| ៣២. | ពិនិត្យ និងកែសម្រួលលិខិតបទដ្ឋានពាក់ព័ន្ធនឹងបង្កើន និងការផ្ទេរធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៣៣. | រៀបចំ និងអនុវត្តគម្រោងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | លេខាធិការដ្ឋាន SNIF |
| ៣៤. | ពង្រឹងការអនុវត្តមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ចនៃ មុខងារនានាដែលបានផ្ទេរទៅឱ្យក្រុង ស្រុក ខណ្ឌ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៣៥. | រៀបចំសេចក្តីណែនាំស្តីពីស្តីពីបែបបទ និងនីតិវិធីផ្តល់សេវារដ្ឋបាល តាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលឃុំ សង្កាត់ | ក្រសួងមហាផ្ទៃ |
| ៣៦. | ពង្រឹងសមត្ថភាពការិយាល័យច្រកចេញចូលតែមួយរាជធានី ខេត្ត | ក្រសួងមហាផ្ទៃ |
| ៣៧. | ពង្រឹងសមត្ថភាពក្រុង ស្រុក ខណ្ឌទាំង២០៤អំពីការផ្តល់សេវានៅការិយាល័យផ្តល់សេវាច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ | ក្រសួងមហាផ្ទៃ |
| ៣៨. | ពង្រឹងយន្តការនានាទទួលខុសត្រូវការងារប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ ជំងឺឆ្លងកាចសាហាវ សេវាសង្គមនៅថ្នាក់លក្រោមជាតិ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៣៩. | ពង្រឹងការតាមដាន និងអនុវត្តគម្រោង កម្មវិធីដាច់ដោយឡែកនានា | គម្រោង កម្មវិធីនានា |

## ៦. សេចក្តីសន្និដ្ឋាន

ទោះបី ការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២១ បានជួបនូវបញ្ហាដ៏ធ្ងន់ធ្ងរនៃការរីករាលដាលជំងឺកូវីដ-១៩ ក៏ដោយ ក៏ស្ថាប័នអនុវត្តទាំងអស់បានខិតខំប្រឹងប្រែងក្នុងការអនុវត្ត ផ.ស.ថ. របស់ខ្លួន និងសម្រេចបានលទ្ធផលគួរជាទីពេញចិត្ត។ ជារួម ការការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២១ សម្រេចបានលទ្ធផល៧៦% ពោលគឺ ក្នុងចំណោមសកម្មភាពជាអាទិភាពទាំង៤២ដែលត្រូវអនុវត្តឆ្នាំ២០២១ រួមមានសកម្មភាពជា អាទិភាព

ចំនួន៣២ត្រូវបានអនុវត្តក្នុងនោះសកម្មភាពជាអាទិភាពចំនួន១១ បានអនុវត្តចប់ និងសម្រេចបាន លទ្ធផល ១០០% និងសកម្មភាពជាអាទិភាពចំនួន២១ ត្រូវបាននិងកំពុងដំណើរការអនុវត្ត។ ដោយឡែក សកម្មភាពជាអាទិភាពដែលមិនបានអវត្តមានចំនួន១០ ដោយសារជួបប្រទះនូវបញ្ហាប្រឈមនានាដូច បានរៀបរាប់ក្នុងផ្នែកទី៤ខាងលើ។

**ឧបសម្ព័ន្ធទី១ ៖**

## វឌ្ឍនភាពលម្អិតនៃការអនុវត្តសកម្មភាពជាអាទិភាពចំនួន៤២ ធៀបនឹងចំណុចដៅដែលគ្រោងទុកក្នុងឆ្នាំ២០២១

| សកម្មភាពជាអាទិភាព និងអនុសកម្មភាព ឬចំណុចដៅដែលត្រូវសម្រេច | ត្រីមាស | | | | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| **ចង្កោមទី១៖ ការដឹកនាំ និងការគ្រប់គ្រងការងារកំណែទម្រង់** | | | | | |
| ១. ការពង្រឹងការអនុវត្ត តួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. និងអនុគណៈកម្មការនានារបស់ គ.ជ.អ.ប. ព្រមទាំងការរៀបចំយន្តការចាំបាច់នានារបស់ គ.ជ.អ.ប. | | | | | ➢ កំពុងដំណើរការ |
| ➢ រៀបចំកិច្ចប្រជុំ គ.ជ.អ.ប. យ៉ាងតិចចំនួន៣លើក ដើម្បីដឹកនាំ ពិភាក្សា និងសម្របសម្រួលកំណែទម្រង់វិមជ្ឈការ និងវិសមជ្ឈការ | | X | X | X | ➢ កំពុងដំណើរការ<br>➢ បានរៀបចំកិច្ចប្រជុំចំនួន០១លើកនៅថ្ងៃទី២១ តុលា ២០២១ |
| ➢ រៀបចំកិច្ចប្រជុំរបស់អនុគណៈកម្មការនីមួយៗ នៃ គ.ជ.អ.ប. យ៉ាងតិចចំនួន៣លើក ដើម្បីរៀបចំ ពិនិត្យ និងផ្តល់យោបល់លើឯកសារនានារបស់កំណែទម្រង់វិមជ្ឈការ និងវិសមជ្ឈការ | | X | X | X | ➢ មិនបានអនុវត្ត<br>➢ |
| ➢ ការរៀបចំ និងដាក់ឱ្យដំណើរការនូវយន្តការចាំបាច់នានារបស់ គ.ជ.អ.ប. ដើម្បីជួយគាំទ្រ គ.ជ.អ.ប. លើការគ្រប់គ្រងគម្រោង និងកម្មវិធីនានា | | | | | ➢ |
| • ក្រុមការងារក្រមសីលធម៌ និងសវនកម្មរបស់ គ.ជ.អ.ប. | | | X | | ➢ កំពុងដំណើរការ<br>➢ បានរៀបចំសេចក្តីព្រាងការបង្កើតក្រុមការងារ |
| • ក្រុមការងារពិនិត្យមើលលទ្ធកម្មរបស់ គ.ជ.អ.ប. | | | X | | ➢ កំពុងដំណើរការ<br>➢ បានរៀបចំសេចក្តីព្រាងការបង្កើតក្រុមការងារ |
| • ក្រុមការងារត្រួតពិនិត្យរបស់ គ.ជ.អ.ប. លើការអនុវត្តការងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប. និងស្ថាប័នអនុវត្តគម្រោងពាក់ព័ន្ធនានា | | | X | | ➢ កំពុងដំណើរការ<br>➢ បានរៀបចំសេចក្តីព្រាងការបង្កើតក្រុមការងារ |
| ២. ការពិនិត្យ កែសម្រួលរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងការពង្រឹងសមត្ថភាពរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីធ្វើជាសេនាធិការ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួល ការគាំទ្រ និងការអនុវត្តកំណែទម្រង់វិមជ្ឈការ | | | | | ➢ កំពុងដំណើរការ |
| ➢ ពិនិត្យមើលឡើងវិញ និងកែសម្រួលរចនាសម្ព័ន្ធ និងតួនាទី ភារកិច្ចរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. | | | | X | ➢ មិនបានអនុវត្ត |
| ➢ ពង្រឹងសមត្ថភាពមន្ត្រីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. | X | X | X | X | ➢ មិនបានអនុវត្ត |
| ➢ ពិនិត្យ និងរៀបចំយន្តការនានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីពង្រឹងការគ្រប់គ្រងកម្មវិធី | | | | | ➢ |

| សកម្មភាពជាអាទិភាព និងអនុសកម្មភាព ឬចំណុចដៅដែលត្រូវសម្រេច | ត្រីមាស | | | | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| • ក្រុមការងារទទួល និងដោះស្រាយពាក្យបណ្ដឹងពាក់ព័ន្ធនឹងការអនុវត្តគម្រោង និងកម្មវិធីនានា | X | | | | ➢ បានបញ្ចប់<br>➢ បង្កើតក្រុមការងារបានបង្កើត |
| • គណៈកម្មការត្រួតពិនិត្យលើលទ្ធកម្មរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. | X | | | | ➢ បានបញ្ចប់<br>➢ គណៈកម្មការបង្កើត និងដាក់ឱ្យដំណើរការ |
| ៣. ការពិនិត្យ និងការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីគាំទ្រ និងអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | | | | | ➢ កំពុងដំណើរការ |
| ➢ ពិនិត្យ និងកែសម្រួលលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន | | | X | | ➢ កំពុងដំណើរការ ៖ ក្រសួងមហាផ្ទៃ និងក្រសួងផ្ទេរមុខងារនានា |
| ➢ ផ្សព្វផ្សាយអំពីលិខិតបទដ្ឋានពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ និងតួនាទី ភារកិច្ចរបស់ក្រសួង ស្ថាប័ន ឬ អង្គភាពនានាដែលបានកែសម្រួល | | | | X | ➢ មិនទាន់អនុវត្ត |
| ៤. ការបង្កើត និងការពង្រឹងយន្តការដឹកនាំ និងការសម្របសម្រួលកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា | | | | | ➢ កំពុងដំណើរការ |
| ➢ បង្កើតយន្តការដឹកនាំ និងសម្របសម្រួលកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ របស់ក្រសួង ស្ថាប័ន | | X | | | ➢ កំពុងដំណើរការ<br>➢ |
| ➢ រៀបចំកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | | | | | ➢ |
| • យ៉ាងតិច ៥០% នៃ គ.ដ.វ.វ. បានរៀបចំកិច្ចប្រជុំរបស់ខ្លួនក្នុងត្រីមាសទី១ | X | | | | ➢ កំពុងដំណើរការ |
| • យ៉ាងតិច ៥០% នៃ គ.ដ.វ.វ. បានរៀបចំកិច្ចប្រជុំរបស់ខ្លួនក្នុងត្រីមាសទី២ | | X | | | ➢ កំពុងដំណើរការ |
| • យ៉ាងតិច ៥០% នៃ គ.ដ.វ.វ. បានរៀបចំកិច្ចប្រជុំរបស់ខ្លួនក្នុងត្រីមាសទី៣ | | | X | | ➢ កំពុងដំណើរការ |
| • យ៉ាងតិច ៥០% នៃ គ.ដ.វ.វ. បានរៀបចំកិច្ចប្រជុំរបស់ខ្លួនក្នុងត្រីមាសទី៤ | | | | X | ➢ កំពុងដំណើរការ |
| ៥. ការពង្រឹងការគ្រប់គ្រងកម្មវិធីកំណែទម្រង់នានានៅថ្នាក់រាជធានី ខេត្ត | | | | | ➢ កំពុងដំណើរការ |
| ➢ រៀបចំកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | | | | | ➢ |
| • យ៉ាងតិច ៥០% នៃ គ.ដ.វ.វ. បានរៀបចំកិច្ចប្រជុំរបស់ខ្លួនក្នុងត្រីមាសទី១ | X | | | | ➢ កំពុងដំណើរការ |
| • យ៉ាងតិច ៥០% នៃ គ.ដ.វ.វ. បានរៀបចំកិច្ចប្រជុំរបស់ខ្លួនក្នុងត្រីមាសទី២ | | X | | | ➢ កំពុងដំណើរការ |
| • យ៉ាងតិច ៥០% នៃ គ.ដ.វ.វ. បានរៀបចំកិច្ចប្រជុំរបស់ខ្លួនក្នុងត្រីមាសទី៣ | | | X | | ➢ កំពុងដំណើរការ |



Vda

| សកម្មភាពជាអាទិភាព និងអនុសកម្មភាព ឬចំណុចដៅដែលត្រូវសម្រេច | ត្រីមាស | | | | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| • យ៉ាងតិច ៥០% នៃ គ.ដ.រ.វ. បានរៀបចំកិច្ចប្រជុំរបស់ខ្លួនក្នុងត្រីមាសទី៤ | | | | X | ➢ កំពុងដំណើរការ |
| **៦. ការពង្រឹងការគ្រប់គ្រងកម្មវិធីកំណែទម្រង់នានានៅថ្នាក់ក្រុង ស្រុក** | | | | | ➢ កំពុងដំណើរការ |
| ➢ រៀបចំកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | | | | | ➢ កំពុងដំណើរការ |
| • យ៉ាងតិច ៥០% គ.ដ.រ.វ. បានរៀបចំកិច្ចប្រជុំរបស់ខ្លួនក្នុងត្រីមាសទី១ | X | | | | ➢ កំពុងដំណើរការ |
| • យ៉ាងតិច ៥០% គ.ដ.រ.វ. បានរៀបចំកិច្ចប្រជុំរបស់ខ្លួនក្នុងត្រីមាសទី២ | | X | | | ➢ កំពុងដំណើរការ |
| • យ៉ាងតិច ៥០% គ.ដ.រ.វ. បានរៀបចំកិច្ចប្រជុំរបស់ខ្លួនក្នុងត្រីមាសទី៣ | | | X | | ➢ កំពុងដំណើរការ |
| • យ៉ាងតិច ៥០% គ.ដ.រ.វ. បានរៀបចំកិច្ចប្រជុំរបស់ខ្លួនក្នុងត្រីមាសទី៤ | | | | X | ➢ កំពុងដំណើរការ |
| **៧. ការពង្រឹងកិច្ចសហការជាមួយកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល** | | | | | ➢ កំពុងដំណើរការ |
| ➢ រៀបចំកិច្ចប្រជុំរវាងលេខាធិការដ្ឋាននៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់រដ្ឋបាល សាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ | X | X | X | X | ➢ កំពុងដំណើរការ<br>➢ បានរៀបចំកិច្ចប្រជុំចំនួន២លើក |
| **៨. ការរៀបចំ និងអនុម័តកម្មវិធីជាតិដំណាក់កាលទី២ (ឆ្នាំ២០២១-២០៣០)** | | | | | ➢ បានបញ្ចប់ |
| ➢ រៀបចំ ពិនិត្យ និងអនុម័តកម្មវិធីជាតិដំណាក់កាលទី២ | | | | | ➢ |
| • ឯកសារសេចក្តីព្រាងកម្មវិធីជាតិដំណាក់កាលទី២ ត្រូវបានរៀបចំបញ្ចប់ | X | | | | ➢ បានបញ្ចប់<br>➢ សេចក្តីព្រាង កជទី២ បានពិនិត្យ និងកែសម្រួល |
| • កម្មវិធីជាតិដំណាក់កាលទី២ ត្រូវបានពិនិត្យ និងអនុម័ត ដោយរាជរដ្ឋាភិបាល | X | | | | ➢ បានបញ្ចប់<br>➢ កជទី២ បានអនុម័តដោយ RGC នៅថ្ងៃទី០៩ ធ្នូ ២០២១ |
| ➢ រៀបចំសិក្ខាសាលាបូកសរុបលទ្ធផលនៃការអនុវត្តកម្មវិធីជាតិដំណាក់កាលទី១ (២០១០-២០២០) និងការផ្សព្វផ្សាយកម្មវិធីជាតិដំណាក់កាលទី២ (២០២១-២០៣០) | | X | | | ➢ បានបញ្ចប់ |
| **៩. ការរៀបចំ និងអនុម័តផែនការអនុវត្តរយៈពេលប្រាំឆ្នាំដំបូង (ផអ៥ទី១) នៃកម្មវិធីជាតិដំណាក់កាលបន្ទាប់** | | | | | ➢ កំពុងដំណើរការ |
| ➢ រៀបចំ និងអនុម័ត ផអ៥ទី១នៃកម្មវិធីជាតិដំណាក់កាលទី២ | | | | | ➢ |
| • ឯកសារសេចក្តីព្រាង ផអ៥ទី១ ត្រូវបានរៀបចំបញ្ចប់ | | X | | | ➢ កំពុងដំណើរការ<br>➢ សេចក្តីព្រាងបឋមនៃ ផអ៥ទី១ បានរៀបចំ |

| សកម្មភាពជាអាទិភាព និងអនុសកម្មភាព ឬចំណុចដៅដែលត្រូវសម្រេច | ត្រីមាស | | | | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| • ផអ៥ទី១ត្រូវបានពិនិត្យ និងអនុម័តដោយ គ.ជ.អ.ប. | | X | | | ➢ កំពុងដំណើរការ<br>➢ ផអ៥ទី១កំពុងពិនិត្យ និងកែសម្រួលដោយលេខាធិការដ្ឋាន គ.ជ.អ.ប. |
| ➢ រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី ផអ៥ទី១នៃកម្មវិធីជាតិដំណាក់កាលទី២ | | | X | | ➢ មិនទាន់អនុវត្ត |
| ➢ រៀបចំយុទ្ធសាស្ត្រ និងបញ្ជីគម្រោងអាទិភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុរយៈពេលមធ្យម សម្រាប់ការអនុវត្តកម្មវិធីជាតិ | | | X | | ➢ បានបញ្ចប់<br>➢ បញ្ជីគម្រោងអាទិភាពរយៈពេលមធ្យមបានធ្វើបច្ចុប្បន្នភាព និងផ្ញើជូន GCF |
| **១០. ការរៀបចំសកម្មភាពនានានៃការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មាន ដើម្បីលើកកម្ពស់ចំណេះដឹង និងការយល់របស់សាធារណជនអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** | | | | | ➢ បានបញ្ចប់ |
| ➢ រៀបចំ ផលិត និងផ្សព្វផ្សាយព័ត៌មាននានាតាមរយៈការបោះពុម្ពផ្សាយ ការចាក់ផ្សាយ និងតាមរយៈបណ្តាញព័ត៌មានសង្គម | | | | | ➢ |
| • ផ្សព្វផ្សាយព័ត៌មានតាមរយៈឯកសារបោះពុម្ពផ្សាយ៖ | | | | | ➢ |
| ○ យ៉ាងតិចចំនួន ១០ ឯកសារ | X | | | | ➢ បានបញ្ចប់ |
| ○ សរុបយ៉ាងតិចចំនួន ៤០ ឯកសារ | | X | | | ➢ បានបញ្ចប់ |
| ○ សរុបយ៉ាងតិចចំនួន ៧០ ឯកសារ | | | X | | ➢ បានបញ្ចប់ |
| ○ សរុបយ៉ាងតិចចំនួន ១០០ ឯកសារព័ត៌មាន | | | | X | ➢ បានបញ្ចប់ |
| • ផ្សព្វផ្សាយព័ត៌មានតាមរយៈឯកសារចាក់ផ្សាយ៖ | | | | | ➢ |
| ○ យ៉ាងតិចចំនួន ២ ឯកសារ | X | | | | ➢ បានបញ្ចប់ |
| ○ សរុបយ៉ាងតិចចំនួន៥ ឯកសារ | | X | | | ➢ បានបញ្ចប់ |
| ○ សរុបយ៉ាងតិចចំនួន ៧ ឯកសារ | | | X | | ➢ បានបញ្ចប់ |
| ○ សរុបយ៉ាងតិចចំនួន ១០ ឯកសារ | | | | X | ➢ បានបញ្ចប់ |
| • ផ្សព្វផ្សាយព័ត៌មានតាមរយៈប្រព័ន្ធអេឡិចត្រូនិច៖ | | | | | ➢ |
| ○ យ៉ាងតិចចំនួន ៣០ ឯកសារព័ត៌មាន | X | | | | ➢ បានបញ្ចប់ |
| ○ សរុបយ៉ាងតិចចំនួន ៧០ ឯកសារព័ត៌មាន | | X | | | ➢ បានបញ្ចប់ |
| ○ សរុបយ៉ាងតិចចំនួន ១០០ ឯកសារព័ត៌មាន | | | X | | ➢ បានបញ្ចប់ |

| សកម្មភាពជាអាទិភាព និងអនុសកម្មភាព ឬចំណុចដៅដែលត្រូវសម្រេច | ត្រីមាស | | | | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| ○ សរុបយ៉ាងតិចចំនួន ១២០ ឯកសារព័ត៌មាន | | | | X | ➢ បានបញ្ចប់ |
| ➢ ផ្សព្វផ្សាយអនុវត្តគោលនយោបាយរបស់ គ.ជ.អ.ប. ស្ដីពីការផ្សព្វផ្សាយព័ត៌មាននានា និងឯកសារ ពាក់ព័ន្ធផ្សេងទៀតជាសាធារណៈ | X | | | | ➢ បានបញ្ចប់<br>➢ គោលនយោបាយបានរៀបចំ និងដាក់ឱ្យអនុវត្ត |
| **១១. ក្របខណ្ឌលទ្ធផលនៃការអនុវត្ត ផអ៥ទី១នៃកម្មវិធីជាតិដំណាក់កាលទី២ ត្រូវបានរៀបចំ និងអនុវត្ត** | | | | | ➢ កំពុងដំណើរការ |
| ➢ រៀបចំ និងអនុម័តក្របខណ្ឌលទ្ធផលនៃការអនុវត្តផអ៥ទី១នៃកម្មវិធីជាតិដំណាក់កាលទី២ | | X | | | ➢ កំពុងដំណើរការ |
| ➢ រៀបចំ និងផ្សព្វផ្សាយក្របខណ្ឌលទ្ធផលនៃការអនុវត្តផអ៥ទី១នៃកម្មវិធីជាតិដំណាក់កាលទី២ និង ឯកសារពាក់ព័ន្ធនានា | | | X | | ➢ មិនទាន់អនុវត្ត |
| ➢ ពិនិត្យ រៀបចំ និងផ្សព្វផ្សាយសមិទ្ធផលនានានៃ កជទី១ | | | X | | ➢ បានបញ្ចប់<br>➢ សេចក្ដីសង្ខេបអំពីសមិទ្ធផលសំខាន់ៗនៃបានរៀបចំ និងផ្សព្វផ្សាយ |
| **១២. ការអនុវត្តការងារសវនកម្មផ្ទៃក្នុងលើការអនុវត្តគម្រោង កម្មវិធីនានាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ លេខាធិការដ្ឋាន គ.ជ.អ.ប.** | | | | | ➢ មិនទាន់អនុវត្ត |
| ➢ រៀបចំ និងផ្សព្វផ្សាយសៀវភៅណែនាំស្ដីពីសវនកម្មផ្ទៃក្នុងរបស់ គ.ជ.អ.ប. | | X | | | ➢ មិនទាន់អនុវត្ត |
| ➢ អនុវត្តការធ្វើសវនកម្មផ្ទៃក្នុងជាទៀងទាត់លើការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២១ | | | | | ➢ |
| • ចំនួនសរុបនៃសវកម្មផ្ទៃក្នុងដែលបានអនុវត្ត ៣លើក | | X | | | ➢ មិនទាន់អនុវត្ត |
| • ចំនួនសរុបនៃសវកម្មផ្ទៃក្នុងដែលបានអនុវត្ត ៦លើក | | | X | | ➢ មិនទាន់អនុវត្ត |
| • ចំនួនសរុបនៃសវកម្មផ្ទៃក្នុងដែលបានអនុវត្ត ៩លើក | | | | X | ➢ មិនទាន់អនុវត្ត |
| **១៣. ការពង្រឹង និងការអនុវត្តនីតិវិធីនានារបស់ គ.ជ.អ.ប. ពាក់ព័ន្ធនឹងគម្រោង កម្មវិធីនានា** | | | | | ➢ កំពុងដំណើរការ |
| ➢ ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តសៀវភៅណែនាំស្ដីអំពីយន្តការ និងនីតិវិធីនៃការទទួល និងដោះស្រាយ បណ្ដឹងពាក់ព័ន្ធនឹងការអនុវត្តគម្រោង និងកម្មវិធីនានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប. | X | | | | ➢ កំពុងដំណើរការ<br>➢ បានរៀបចំសេចក្ដីព្រាងនីតិវិធីសម្រុះសម្រួលដោះស្រាយបណ្ដឹង |
| ➢ ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តគោលនយោបាយស្ដីពីសុវត្ថិភាពបរិស្ថាន និងសង្គមនៃគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ | | X | | | ➢ បានបញ្ចប់<br>➢ បានរៀបចំ និងផ្សព្វផ្សាយសេចក្ដីណែនាំសម្រាប់សាកល្បងការបញ្ជ្រាប គោលសុវត្ថិភាពបរិស្ថា និងសង្គម និងគោលនយោបាយសមភាពយេនឌ័រ ក្នុងការគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅខែធ្នូ ២០២១ |

| សកម្មភាពជាអាទិភាព និងអនុសកម្មភាព ឬចំណុចដៅដែលត្រូវសម្រេច | ត្រីមាស | | | | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| ១៤. ការពង្រឹង និងគាំទ្រសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | | | | | ➢ បានបញ្ចប់ |
| ➢ រៀបចំកិច្ចប្រជុំអង្គអភិបាលកិច្ចរបស់សមាគមជាតិយ៉ាងតិចចំនួន៨លើក | | | | | ➢ |
| • ចំនួនសរុបរួមនៃកិច្ចប្រជុំយ៉ាងតិចចំនួន ២ លើកបានរៀបចំ | X | | | | ➢ បានបញ្ចប់ |
| • ចំនួនសរុបរួមនៃកិច្ចប្រជុំយ៉ាងតិចចំនួន ៤ លើកបានរៀបចំ | | X | | | ➢ បានបញ្ចប់ |
| • ចំនួនសរុបរួមនៃកិច្ចប្រជុំយ៉ាងតិចចំនួន ៦ លើកបានរៀបចំ | | | X | | ➢ បានបញ្ចប់ |
| • ចំនួនសរុបរួមនៃកិច្ចប្រជុំយ៉ាងតិចចំនួន ៨ លើកបានរៀបចំ | | | | X | ➢ បានបញ្ចប់ |
| ➢ រៀបចំកិច្ចប្រជុំអង្គអភិបាលកិច្ចរបស់សម្ព័ន្ធភាពជាតិយ៉ាងតិចចំនួន៦លើក | | | | | ➢ |
| • ចំនួនសរុបរួមនៃកិច្ចប្រជុំយ៉ាងតិចចំនួន ១ លើកបានរៀបចំ | X | | | | ➢ បានបញ្ចប់ |
| • ចំនួនសរុបរួមនៃកិច្ចប្រជុំយ៉ាងតិចចំនួន ៣ លើកបានរៀបចំ | | X | | | ➢ បានបញ្ចប់ |
| • ចំនួនសរុបរួមនៃកិច្ចប្រជុំយ៉ាងតិចចំនួន ៤ លើកបានរៀបចំ | | | X | | ➢ បានបញ្ចប់ |
| • ចំនួនសរុបរួមនៃកិច្ចប្រជុំយ៉ាងតិចចំនួន ៦ លើកបានរៀបចំ | | | | X | ➢ បានបញ្ចប់ |
| **ចង្កោមទី២៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | ➢ |
| ១៥. ការបន្តគាំទ្រ និងពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក | | | | | ➢ កំពុងដំណើរការ |
| ➢ ចុះគាំទ្រ និងត្រួតពិនិត្យការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក | X | X | X | X | ➢ កំពុងដំណើរការ<br>➢ បានចុះតាមដាន និងគាំទ្រការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក |
| ➢ រៀបចំ និងប្រមូលទិន្នន័យដើមគ្រាពាក់ព័ន្ធនឹងការអនុវត្តមុខងារក្នុងវិស័យសំខាន់ៗមួយចំនួនរបស់ រដ្ឋបាលក្រុង ស្រុក | | | X | | ➢ មិនទាន់អនុវត្ត |
| ➢ រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងមុខងាររបស់រដ្ឋបាលក្រុង ស្រុក | | | | X | ➢ មិនទាន់អនុវត្ត |
| ១៦. ការសិក្សា វាយតម្លៃលើរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ខេត្ត ដើម្បីកែសម្រួលឱ្យក្លាយទៅជា រដ្ឋបាលតំបន់ | | | | | ➢ មិនទាន់អនុវត្ត |
| ➢ សិក្សាស្រាវជ្រាវ ប្រមូលចងក្រងមេរៀនបទពិសោធពីបណ្តាប្រទេសនានា | | | X | | ➢ មិនទាន់អនុវត្ត |

| សកម្មភាពជាអាទិភាព និងអនុសកម្មភាព ឬចំណុចដៅដែលត្រូវសម្រេច | ត្រីមាស | | | | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| ➢ រៀបចំក្របខណ្ឌទស្សនទានអំពីជម្រើសនានាសម្រាប់រដ្ឋបាលខេត្ត | | | | X | ➢ មិនទាន់អនុវត្ត |
| **១៧. ការពង្រឹងការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | ➢ កំពុងដំណើរការ |
| ➢ ពិនិត្យមើលឡើងវិញ និងពង្រឹងនីតិវិធីបំពេញការងាររបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | | X | | | ➢ កំពុងដំណើរការ<br>➢ កំពុងពិនិត្យ និងកែសម្រួលលិខិតបទដ្ឋានពាក់ព័ន្ធនឹងយន្តការ និងនីតិវិធី នានានៃការបំពេញការងាររបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ |
| ➢ ពិនិត្យ និងកែសម្រួលយន្តការផ្តល់យោបល់របស់ក្រុមប្រឹក្សា | | | X | | ➢ មិនទាន់អនុវត្ត |
| ➢ បង្កើតកញ្ចប់ថវិកាជាក់លាក់សម្រាប់គាំទ្រដល់កិច្ចប្រតិបត្តិការរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការរបស់ក្រុមប្រឹក្សា | | | | X | ➢ មិនទាន់អនុវត្ត |
| ➢ អភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សាក្នុងការដឹកនាំ ការធ្វើសេចក្តីសម្រេចចិត្ត ការតាមដានត្រួតពិនិត្យ លើការអនុវត្តសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា | | | X | X | ➢ បានបញ្ចប់ |
| **១៨. ការសិក្សាអំពីលទ្ធភាពនៃការរៀបចំ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យានៅរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | ➢ កំពុងដំណើរការ |
| ➢ សិក្សាលទ្ធភាពក្នុងការរៀបចំ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យានៅរដ្ឋបាលថ្នាក់ក្រោមជាតិ | | | | X | ➢ បានបញ្ចប់<br>➢ ការសិក្សាត្រូវបានអនុវត្ត |
| ➢ រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើកិច្ចការមួយចំនួន | | | | X | ➢ កំពុងដំណើរការ<br>➢ កំពុងដំណើរការរៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| **ចង្កោមទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស** | | | | | ➢ |
| **១៩. ការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | ➢ កំពុងដំណើរការ |
| ➢ សិក្សា និងរៀបចំប្រព័ន្ធគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា | | X | | | ➢ កំពុងដំណើរការ |
| ➢ រៀបចំ និងដាក់ឱ្យអនុវត្តនូវអង្គមន្ត្រីរាជការស៊ីវិល | | | X | | ➢ មិនទាន់អនុវត្ត |
| ➢ រៀបចំការពិពណ៌នាមុខតំណែងរបស់បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | X | | | ➢ កំពុងដំណើរការ<br>➢ ការពិពណ៌នាអំពីមុខតំណែង និងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិកក្រុង ស្រុក ខណ្ឌចំនួន៥៣មុខតំណែងត្រូវបានរៀបចំ ដោយក្រសួងមុខងារសាធារណៈ |

| សកម្មភាពជាអាទិភាព និងអនុសកម្មភាព ឬចំណុចដៅដែលត្រូវសម្រេច | ត្រីមាស | | | | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| | | | | | សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. និងដោយមានការគាំទ្រថវិកា របស់ DAR/GIZ |
| ➢ វាយតម្លៃ និងកំណត់តម្រូវការធនធានមនុស្ស (ចំនួនបុគ្គលិកនិងចំនួនមុខតំណែងវិជ្ជាជីវៈ) សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | | | | X | ➢ មិនទាន់អនុវត្ត |
| ➢ រៀបចំក្រមសីលធម៌សម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | | X | | | ➢ កំពុងដំណើរការ<br>➢ កំពុងដំណើរការពិនិត្យ និងរៀបចំក្រមសីលធម៌សម្រាប់បុគ្គលិក |
| ➢ ពិនិត្យ និងកែសម្រួលគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិកនៅថ្នាក់ក្រោមជាតិ | | | X | | ➢ បានបញ្ចប់<br>➢ គោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិកនៅថ្នាក់ក្រោមជាតិ ដែលបានដាក់ចេញក្នុងឆ្នាំ២០១៨ ត្រូវបានពិនិត្យ និងកែសម្រួល ស្របតាមរចនាសម្ព័ន្ធ និងមុខងារថ្មីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ➢ រៀបចំ និងដាក់អនុវត្តប្រព័ន្ធគ្រប់គ្រងបុគ្គលិកផ្អែកលើសមិទ្ធកម្ម | | | | X | ➢ កំពុងដំណើរការ<br>➢ កំពុងដំណើរការពិនិត្យ និងរៀបចំប្រព័ន្ធគ្រប់គ្រងបុគ្គលិកផ្អែកលើសមិទ្ធកម្ម |
| ➢ សិក្សា និងរៀបចំអំពីគោលនយោបាយលើកទឹកចិត្តដល់បុគ្គលិកនៅថ្នាក់ក្រោមជាតិ | | | | X | ➢ មិនទាន់អនុវត្ត |
| **២០. ការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | ➢ កំពុងដំណើរការ |
| ➢ ពង្រឹងស្ថាប័នបណ្តុះបណ្តាលនៅថ្នាក់ជាតិ (សាលាជាតិរដ្ឋបាលមូលដ្ឋាន) | | | | | ➢ |
| • ការសិក្សាគម្រោងសាងសង់អគារសាលាជាតិរដ្ឋបាលមូលដ្ឋាន | | | | X | ➢ បានបញ្ចប់ |
| • រៀបចំវគ្គបណ្តុះបណ្តាលកាតព្វកិច្ចសម្រាប់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | | X | X | X | ➢ កំពុងដំណើរការ<br>➢ បានរៀបចំវគ្គបណ្តុះបណ្តាល |
| • រៀបចំវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស (ពីគោលការណ៍ នីតិវិធី បែបបទ និងស្តង់ដា នៃការផ្តល់សេវា) ដល់មន្ត្រីជំនាញនៅថ្នាក់ក្រុង ស្រុក ខណ្ឌ | | X | X | X | ➢ កំពុងដំណើរការ<br>➢ បានរៀបចំវគ្គបណ្តុះបណ្តាល |
| • រៀបចំសេចក្តីព្រាងអំពីវិធីសាស្ត្របណ្តុះបណ្តាលជាក់លាក់មួយចំនួន (ការបណ្តុះបណ្តាលតាមអនឡាញ និងការរៀបចំបរិយាកាសរៀនសូត្រនៅហ្នឹងកន្លែងធ្វើការ) | | | | X | ➢ មិនទាន់អនុវត្ត |
| ➢ សិក្សាលទ្ធភាពនៃការបង្កើតសាលាបណ្តុះបណ្តាលថ្នាក់តំបន់ | | | | | ➢ មិនទាន់អនុវត្ត |
| ➢ រៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពដល់ក្រុង ស្រុក ខណ្ឌ ដោយរដ្ឋបាលរាជធានី ខេត្ត | | | | | ➢ |

| សកម្មភាពជាអាទិភាព និងអនុសកម្មភាព ឬចំណុចដៅដែលត្រូវសម្រេច | ត្រីមាស | | | | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| ○ ភាគរយសរុបនៃកម្មវិធីអភិវឌ្ឍសមត្ថភាពដែលបានអនុវត្ត ១០% | X | | | | ➢ កំពុងដំណើរការ |
| ○ ភាគរយសរុបនៃកម្មវិធីអភិវឌ្ឍសមត្ថភាពដែលបានអនុវត្ត ៣០% | | X | | | ➢ កំពុងដំណើរការ |
| ○ ភាគរយសរុបនៃកម្មវិធីអភិវឌ្ឍសមត្ថភាពដែលបានអនុវត្ត ៥០% | | | X | | ➢ កំពុងដំណើរការ |
| ○ ភាគរយសរុបនៃកម្មវិធីអភិវឌ្ឍសមត្ថភាពដែលបានអនុវត្ត ៧០% | | | | X | ➢ កំពុងដំណើរការ<br>➢ បានរៀបចំសកម្មភាពអភិវឌ្ឍសមត្ថភាពជាង៥០០សកម្មភាព |
| ➢ រៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពដល់ក្រុង ស្រុក ខណ្ឌ ដោយមន្ទីរអង្គភាពជំនាញ | | | | | ➢ |
| ○ ភាគរយសរុបនៃកម្មវិធីអភិវឌ្ឍសមត្ថភាពដែលបានអនុវត្ត ១០% | X | | | | ➢ កំពុងដំណើរការ |
| ○ ភាគរយសរុបនៃកម្មវិធីអភិវឌ្ឍសមត្ថភាពដែលបានអនុវត្ត ៣០% | | X | | | ➢ កំពុងដំណើរការ |
| ○ ភាគរយសរុបនៃកម្មវិធីអភិវឌ្ឍសមត្ថភាពដែលបានអនុវត្ត ៥០% | | | X | | ➢ កំពុងដំណើរការ |
| ○ ភាគរយសរុបនៃកម្មវិធីអភិវឌ្ឍសមត្ថភាពដែលបានអនុវត្ត ៧០% | | | | X | ➢ កំពុងដំណើរការ<br>➢ រាប់បញ្ចូលជាមួយសកម្មភាពអភិវឌ្ឍសមត្ថភាពជាង៥០០សកម្មភាពខាងលើ |
| **២១. ការអនុវត្តកម្មវិធីស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | ➢ កំពុងដំណើរការ |
| ➢ អភិវឌ្ឍសមត្ថភាពរបស់ស្ត្រីក្នុងមុខតំណែងដឹកនាំដោយសហការជាមួយភាគីពាក់ព័ន្ធនានា | | X | | | ➢ កំពុងដំណើរការ<br>➢ បានរៀបចំឯកសារសម្រាប់វគ្គបណ្តុះបណ្តាល |
| **២២. ការអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាព និងការបង្កើនចំណេះដឹងរបស់ថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិអំពី បរិយាប័ន្ន និងសមធម៌សង្គម** | | | | | ➢ កំពុងដំណើរការ<br>➢ |
| ➢ ពិនិត្យ និងកែសម្រួលឯកសារបណ្តុះបណ្តាលជាកាតព្វកិច្ចសម្រាប់ថ្នាក់ដឹកនាំរាជធានី ខេត្ត | X | | | | ➢ កំពុងដំណើរការ<br>➢ បានរៀបចំឯកសារសម្រាប់វគ្គបណ្តុះបណ្តាល |
| ➢ រៀបចំវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចសម្រាប់ថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់រាជធានី ខេត្ត | | | X | | ➢ កំពុងដំណើរការ<br>➢ រាប់បញ្ចូលជាមួយសកម្មភាពអភិវឌ្ឍសមត្ថភាពជាង៥០០សកម្មភាពខាងលើ |
| ➢ រៀបចំវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចសម្រាប់ថ្នាក់ដឹកនាំក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធនានា | | | | X | ➢ កំពុងដំណើរការ<br>➢ រាប់បញ្ចូលជាមួយសកម្មភាពអភិវឌ្ឍសមត្ថភាពជាង៥០០សកម្មភាពខាងលើ |

| សកម្មភាពជាអាទិភាព និងអនុសកម្មភាព ឬចំណុចដៅដែលត្រូវសម្រេច | ត្រីមាស | | | | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| ២៣. ការបញ្ជ្រាបបរិយាប័ន្ន និងសមធម៌សង្គមក្នុងកិច្ចដំណើរការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | | | | ➢ កំពុងដំណើរការ |
| ➢ រៀបចំ និងផ្សព្វផ្សាយគោលនយោបាយស្តីពីការលើកកម្ពស់យេនឌ័រក្នុងការងារកំណែទម្រង់ | | X | | | ➢ មិនទាន់អនុវត្ត |
| ➢ វគ្គបណ្តុះបណ្តាលស្តីពីការលើកកម្ពស់យេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម | | | X | | ➢ កំពុងដំណើរការ<br>➢ រាប់បញ្ចូលជាមួយសកម្មភាពអភិវឌ្ឍសមត្ថភាពជាង៥០០សកម្មភាពខាងលើ |
| **ចង្កោមទី៤៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការថ្នាក់ក្រោមជាតិ** | | | | | ➢ |
| ២៤. ពិនិត្យ និងកែសម្រួលប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក | | | | | ➢ បានបញ្ចប់ |
| ➢ ពិនិត្យ និងកែសម្រួលប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក | | | X | | ➢ បានបញ្ចប់<br>➢ ក្រុង ស្រុក ខណ្ឌអនុវត្តនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុស្របតាមរចនាសម្ព័ន្ធ និង មុខងារថ្មីរបស់ខ្លួនដែលបានកែសម្រួល |
| ២៥. ការពិនិត្យ និងការកែសម្រួលរូបមន្ត និងលក្ខណៈវិនិច្ឆ័យនៃការវិភាជធនធានហិរញ្ញវត្ថុសម្រាប់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ | | | | | ➢ មិនទាន់អនុវត្ត |
| ➢ សិក្សា និងកំណត់អំពីរូបមន្ត និងលក្ខណៈវិនិច្ឆ័យនៃការវិភាជធនធានហិរញ្ញវត្ថុសម្រាប់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ | | | | X | ➢ មិនទាន់អនុវត្ត |
| ➢ ពិនិត្យ និងកែសម្រួលលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាស្តីពីធនធានរដ្ឋបាលថ្នាក់ក្រោមជាតិ | | | | X | ➢ មិនទាន់អនុវត្ត |
| ២៦. ការពិនិត្យមើលឡើងវិញអំពីអត្រានៃការបែងចែកធនធានហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | | | | | ➢ មិនទាន់អនុវត្ត |
| ➢ ពិនិត្យមើលឡើងវិញអំពីអត្រានៃការបែងចែកធនធានហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | | | X | | ➢ មិនទាន់អនុវត្ត |
| ២៧. ការគាំទ្រ និងពង្រឹងការគ្រប់គ្រង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុមានភ្ជាប់ល័ក្ខខ័ណ្ឌសម្រាប់ការអនុវត្ត មុខងារដែលបានផ្ទេរ ស្របតាមផែនការការងារ និងក្របខ័ណ្ឌពេលវេលានៃការផ្ទេរមុខងារ | | | | | ➢ បានបញ្ចប់<br>➢ |
| ➢ គាំទ្រ និងផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់ល័ក្ខខ័ណ្ឌសម្រាប់វិស័យសុខាភិបាល | X | | | | ➢ បានបញ្ចប់<br>➢ បានផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់ល័ក្ខខ័ណ្ឌសម្រាប់វិស័យសុខាភិបាលទៅឱ្យរាជធានី ខេត្តទាំង២៥ |
| ➢ គាំទ្រ និងផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់ល័ក្ខខ័ណ្ឌសម្រាប់វិស័យអប់រំ | X | | | | ➢ បានបញ្ចប់ |

| សកម្មភាពជាអាទិភាព និងអនុសកម្មភាព ឬចំណុចដៅដែលត្រូវសម្រេច | ត្រីមាស | | | | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | |
| | | | | | ➢ បានផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់ល័ក្ខខ័ណ្ឌសម្រាប់ការិយាល័យអប់រំក្រុង ស្រុក ខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំង២០៤ទូទាំងប្រទេស |
| **២៨. គម្រោងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៥៥ ត្រូវបានរៀបចំ និងអនុវត្ត** | | | | | ➢ បានបញ្ចប់ |
| ➢ រៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកិច្ចប្រតិបត្តិការរបស់លេខាធិការដ្ឋាន គ.ជ.ក. | | X | | | ➢ បានបញ្ចប់<br>➢ បានរៀបចំវគ្គផ្សព្វផ្សាយ |
| ➢ ផ្តល់ធនធានគាំទ្រមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់វិនិយោគសាធារណៈ | | | X | | ➢ បានបញ្ចប់<br>➢ គម្រោងបានរៀបចំ និងអនុវត្ត |
| ➢ ផ្តល់ធនធានគាំទ្រមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់វិនិយោគសាធារណៈ (កម្ចី ADB) | | | X | | ➢ បានបញ្ចប់<br>➢ គម្រោងបានរៀបចំ និងអនុវត្ត |
| **២៩. ការបង្កើនប្រភពចំណូលបន្ថែមដើម្បីប្រគល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | ➢ មិនទាន់អនុវត្ត |
| ➢ សិក្សាអំពីលទ្ធភាពនៃការបង្កើនប្រភពចំណូលរដ្ឋបាលថ្នាក់ក្រោមជាតិ | | | | X | ➢ មិនទាន់អនុវត្ត |
| **៣០. ការពិនិត្យមើលឡើងវិញនូវប្រព័ន្ធគ្រប់គ្រងថវិការបស់រដ្ឋបាលថ្នាក់រាជធានី ខេត្ត** | | | | | ➢ មិនទាន់អនុវត្ត |
| ➢ សិក្សាលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រាជធានី ខេត្ត | | | | X | ➢ មិនទាន់អនុវត្ត |
| **៣១. ការរៀបចំស្តង់ដានិងនីតិវិធីសម្រាប់ធ្វើសវនកម្មផ្ទៃក្នុងលើការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | ➢ មិនទាន់អនុវត្ត |
| ➢ សិក្សាស្តង់ដានិងនីតិវិធីសម្រាប់ធ្វើសវនកម្មផ្ទៃក្នុងលើការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | | | X | ➢ មិនទាន់អនុវត្ត |
| **៣២. ការពិនិត្យ និងកែសម្រួលកិច្ចដំណើរការនៃការកសាងផែនការអភិវឌ្ឍ៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល (ការផ្សារភ្ជាប់គ្នារវាងការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលជាមួយជានឹងការកសាងផែនការយុទ្ធសាស្ត្រថវិកា ស្របទៅនឹងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក)** | | | | | ➢ កំពុងដំណើរការ |
| ➢ ពិនិត្យ និងការកែសម្រួលកិច្ចដំណើរការនៃការកសាងផែនការអភិវឌ្ឍ៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា | | | | X | ➢ មិនទាន់អនុវត្ត |
